E72/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 12 / OCT / 2009
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Fuy

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អវតក/អជសដ
**Case File/Dossier No. 001/18-07-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **ធូ មណី**

កាលបរិច្ឆេទ: ថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០០៩
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 12 / OCT / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Fuy

# សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹង រដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំ ទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅ ឲ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ

**សហព្រះរាជអាជ្ញា**
ជា លាង
William SMITH (ស្តីទី)

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ ហៅ ឌុច

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C.

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥) -២៣-២១៩-៨១៤ ទូរសារ: (៨៥៥) -២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh
National Road 4 ,Chaom Chau , Dangkao Phnom Penh Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941 Web: www.eccc.gov.kh

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE

ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN
Fabienne TRUSSES-NAPROUS
Christine MATINEAU

**មេធាវីជនជាប់ចោទ**

ការ សាវុត្ថ
François ROUX
Marie-Paule CANIZARÈS

E72/3

០០១/១៨ កក្កដា ២០០៧/អវតក/អជសដ

## I. សេចក្ដីផ្ដើម

១. នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ និងក្រុម២ បានដាក់សំណើរួមគ្នាមួយនៅក្នុងសំណុំរឿងលេខ០០១ មកអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅកាត់ថា "អ.វ.ត.ក") ដោយស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តា "សម្រេចអនុញ្ញាតឱ្យមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីឡើងធ្វើសេចក្ដីសន្និដ្ឋានស្ដីពីការផ្ដន្ទាទោសជនជាប់ចោទ"។ តាមការអះអាងដោយផ្ទាល់មាត់ និងដោយលាយលក្ខណ៍អក្សរ មេធាវីការពារបានជំទាស់ទៅនឹងការស្នើសុំបែបនេះ ដោយបានលើកឡើងថាដើមបណ្ដឹងរដ្ឋប្បវេណីមិនមានតួនាទីអ្វីទាក់ទងនឹងការផ្ដន្ទាទោសជនជាប់ចោទនោះទេ[1]។ នៅក្នុងចម្លើយតបរបស់ខ្លួនកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ការិយាល័យសហព្រះរាជអាជ្ញាមិនបានបញ្ចេញជំហររបស់ខ្លួនចំពោះសិទ្ធិរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការដាក់សេចក្ដីសន្និដ្ឋានទាក់ទងនឹងការផ្ដន្ទាទោសនោះទេ ប៉ុន្តែគ្រាន់តែការិយាល័យសហព្រះរាជអាជ្ញា សង្កេត ឃើញថា ច្បាប់ជាធរមានដែលអនុវត្តនៅចំពោះមុខ អ.វ.ត.ក មិនមានចែងអំពីការហាមឃាត់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការដាក់សេចក្ដីសន្និដ្ឋានបែបនេះ នោះទេ[2]។ នៅក្នុងចម្លើយតបរបស់ខ្លួនកាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ មេធាវីការពារបានលើកឡើង

[1] "ក្រុម ១ និង ២ - សំណើរួមរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំឱ្យចេញសេចក្ដីសម្រេចលើសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្ដីសន្និដ្ឋានអំពីការផ្ដន្ទាទោស" (ឯកសារ E72) (ចាប់ពីនេះតទៅហៅថា "សំណើរួម") កថាខណ្ឌទី១, ៣, និង៤ ព្រមទាំងជើងទំព័រ ១, ២, ៥ ដល់ ១២។

[2] "ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរួមរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនសុំឱ្យចេញសេចក្ដីសម្រេចលើសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្ដីសន្និដ្ឋានអំពីការផ្ដន្ទាទោស" ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ឯកសារ E72/1)។



* អង្គជំនុំជម្រះសាលាដំបូង * TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • C E T C

E72/3



ជាថ្មីនូវការជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការផ្តន្ទាទោសនេះ[3]។ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចលើសំណើសុំទាំងនេះដូចខាងក្រោម៖

តាមមតិភាគច្រើនរបស់ចៅក្រម និងមតិជំទាស់ដោយផ្នែករបស់ចៅក្រមLavergne អង្គជំនុំជម្រះសាលាដំបូងសម្រេចដូចខាងក្រោម៖

១. បដិសេធ សំណើរួមរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ និងក្រុម២ ។

២. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺមិនអនុញ្ញាតឱ្យធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹងការផ្តន្ទាទោស រួមទាំង

ក. សេចក្តីសន្និដ្ឋានផ្តន្ទាទោសទៅលើជនជាប់ចោទ

ខ. សេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់អំពីការផ្តន្ទាទោស និង

គ. សេចក្តីសន្និដ្ឋាន ឬការវាយតម្លៃនូវកត្តាទាំងឡាយដែលត្រូវសម្រេចសេចក្តីអំពីការផ្តន្ទាទោស។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីគឺអនុញ្ញាតឱ្យយោងទៅលើអង្គហេតុទាំងនោះ តែក្នុងករណីដែលត្រូវយោងទៅលើពិរុទ្ធភាព ឬ គ្មានពិរុទ្ធរបស់ជនជាប់ចោទ ឬការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ[4]។

២. នៅក្នុងសវនាការដដែលនេះដែរ អង្គជំនុំជម្រះសាលាដំបូងបានស្នើដល់ភាគីនានាឱ្យលើកឡើងនូវអំណះអំណាងផ្ទាល់មាត់ទាក់ទងនឹងសំណួរដូចខាងក្រោម៖

---

[3] "ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើសុំតែមួយរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ និងក្រុម២ ដែលស្នើសុំឱ្យអង្គជំនុំជម្រះសម្រេចលើលក្ខណៈសម្បត្តិ របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើកំណត់សម្គាល់លើសំណួរ ដែលពាក់ព័ន្ធទៅនឹងការកំណត់ទោស" (ឯកសារ E72/2) កថាខណ្ឌទី ៧ ("ចម្លើយតបរបស់មេធាវីការពារក្តី")។

[4] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ (ឯកសារ E1/70.1) ទំព័រ ៤២។

តើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គួរត្រូវបានអនុញ្ញាតឱ្យសួរសំណួរដល់ជនជាប់ចោទ និងសាក្សីដែលត្រូវកោះហៅមកផ្តល់សក្ខីកម្មលើផ្នែកមួយនៃសវនាការដែលមានកម្មវត្ថុ "ការសួរសំណួរដល់សាក្សី និងអ្នកជំនាញ លើបញ្ហាទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ" ដែរឬទេ?" ដោយយោងតាមដីកាសម្រេចកំណត់កាលវិភាគសវនាការរបស់អង្គជំនុំជម្រះចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០៩[5]។

៣. ក្រោយពីបានស្តាប់តំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារជួចមក តាមមតិភាគច្រើនរបស់ចៅក្រម និងមតិជំទាស់របស់ចៅក្រម Lavergne អង្គជំនុំជម្រះសម្រេចផ្ទាល់មាត់ដូចខាងក្រោម៖

ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឱ្យសួរសំណួរពាក់ព័ន្ធនឹងអត្តចរិតរបស់ជនជាប់ចោទ និងសាក្សីដែលមានរហស្សនាម និងឈ្មោះ៖ KW-34 និង Francoise Seroni Guilbaud, D1, D2, D3, D4, D5, D6, Christopher Lapel, D8 និង D14[6]។

## II. សំណើ និង ការឆ្លើយតបរបស់ភាគីនានា

### ក. ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការផ្តន្ទាទោស

[5] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ទំព័រ ៤២ ដល់ ៤៣ "ដីកាកំណត់កាលវិភាគនៃដំណើការសវនាការ (អង្គហេតុ និងលំដាប់នៃការកោះហៅសាក្សី) សម្រាប់រយៈពេលពីថ្ងៃទី ១៧ ខែសីហា ដល់ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០០៩" ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០០៩ (ឯកសារ E138)។

[6] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ទំព័រ ៧៤។



TRIAL CHAMBER · CHAMBRE DE PREMIÈRE INSTANCE · E C C C · E T C

៤. ក្នុងការគាំទ្រលើសំណើរបស់ខ្លួន មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ និងក្រុម២ បានអះអាងថា អង្គហេតុពាក់ព័ន្ធនឹងពិរុទ្ធភាព និងគ្មានពិរុទ្ធរបស់ជនជាប់ចោទ មិនអាចកាត់ផ្ដាច់ពីអង្គហេតុដែលពាក់ព័ន្ធនឹងការផ្ដន្ទាទោសបានទេ។ ហេតុដូច្នេះ ការវាយតម្លៃអំពីការពិចារណាទាំងនោះ មិនត្រឹមតែមានផលប៉ះពាល់លើពិរុទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែវាប៉ះពាល់ចាំបាច់លើការផ្ដន្ទាទោសផងដែរ[7]។ បទប្បញ្ញត្តិនៅក្នុងអត្ថបទច្បាប់របស់ អ.វ.ត.ក មិនបានហាមឃាត់ការដាក់សេចក្ដីសន្និដ្ឋានស្ដីពីការផ្ដន្ទាទោសទេ។ ផ្ទុយទៅវិញ បទប្បញ្ញត្តិច្បាប់មួយចំនួនដែលពាក់ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណី អនុញ្ញាតដោយប្រយោលឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដាក់សេចក្ដីសន្និដ្ឋានស្ដីពីការផ្ដន្ទាទោស។ ឧទាហរណ៍ វិធាន២៣(១)(ក) នៃវិធានផ្ទៃក្នុង ចែងថា គោលបំណងនៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីគឺគាំទ្រដល់ការចោទប្រកាន់។ ដំណើរការនីតិវិធីចំពោះមុខអ.វ.ត.ក មិនបានចែងអំពីសវនាការផ្ដន្ទាទោសមួយដាច់ដោយឡែកនោះទេ ចំណែកឯវិធានផ្ទៃក្នុងរបស់អ.វ.ត.ក វិញ ក៏មិនបានចែងឲ្យច្បាស់អំពីការកំរិតសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹងការផ្ដន្ទាទោសនោះដែរ។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីលើកអំណះអំណាងថា ច្បាប់របស់ប្រទេសកម្ពុជា ក៏អនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសេចក្ដីសន្និដ្ឋានទាក់ទិននឹងការផ្ដន្ទាទោសផងដែរ[8]។

៥. ម្យ៉ាងវិញទៀត វិធាននីតិវិធីដែលចែងនៅក្នុងកម្រិតអន្តរជាតិ អនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមក្នុងការធ្វើសេចក្ដីដ្ឋានទាក់ទិននឹងការផ្ដន្ទាទោស។ សំអាងនេះយោងលើសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (“ICC”) ដែលដាក់ដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដែលសេចក្ដីសម្រេចនេះចែងអំពីការចូលរួមរបស់ជនរងគ្រោះនៅក្នុងការផ្ដន្ទាទោស[9]។

---

[7] សំណើសុំរួម កថាខណ្ឌ ៦-៨។

[8] សំណើសុំរួម កថាខណ្ឌ ៩-១៤។

[9] សំណើសុំរួម កថាខណ្ឌ១៦, ១៧។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C

៦. ចំណុចចុងក្រោយគឺថា ដោយសារតែសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ផ្អែកលើការបាត់បង់សាច់ញាតិដោយមូលហេតុមកពីបទល្មើសដែលចោទប្រកាន់ ដូចនេះដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើននៅក្នុងសំណុំរឿងលេខ០០១ មិនបានដឹងអំពីអង្គហេតុដែលទាក់ទិននឹងពិរុទ្ធភាព ឬគ្មានពិរុទ្ធរបស់ជនជាប់ចោទទេ។ ហេតុនេះ សេចក្តីថ្លែងការណ៍របស់ពួកគេពិតជាអាចមានឥទ្ធិពលដល់ការផ្តន្ទាទោស និងមិនត្រឹមតែមានផលប៉ះពាល់លើពិរុទ្ធភាព ឬគ្មានពិរុទ្ធរបស់ជនជាប់ចោទនោះទេ[10]។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក៏ប្រឆាំងនឹងអំណះអំណាងរបស់មេធាវីការពារដែលលើកឡើងថា នៅក្នុងតុលាការប្រទេសបារាំង ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឱ្យដាក់សេចក្តីសន្និដ្ឋានស្តីពីការផ្តន្ទាទោស និងបានជំទាស់នឹងការដែលថាពួកគេមិនអាចលើកយកយុត្តិសាស្ត្របារាំងមកធ្វើជាសំអាងបាននោះ[11]។ លើសពីនេះ យុត្តាធិការផ្សេងៗអនុញ្ញាតឱ្យមានការចូលរួមរបស់ជនរងគ្រោះទាក់ទិននឹងការផ្តន្ទាទោស និងអនុញ្ញាតឱ្យប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការផ្តន្ទាទោសទៀតផង[12]។

៧. នៅក្នុងចម្លើយតបរបស់ខ្លួន មេធាវីការពារបានលើកអំណះអំណាងថា ក្រោមបទប្បញ្ញត្តិនៃច្បាប់ព្រះរាជាណាចក្រកម្ពុជា និងក្រោមវិធានផ្ទៃក្នុងរបស់អ.វ.ត.ក បញ្ហាទាក់ទិននឹងការផ្តន្ទាទោស គឺស្ថិតនៅក្នុងសមត្ថកិច្ចរបស់អយ្យការទាំងស្រុង។ សេចក្តីសន្និដ្ឋាននេះ បានបញ្ជាក់ដោយវិធាន១០៥ នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិប្តឹងឧទ្ធរណ៍តែក្នុងករណីដែលមានការពាក់ព័ន្ធនឹង "ផលប្រយោជន៍រដ្ឋប្បវេណី" របស់ពួកគាត់[13]។ គោលការណ៍ដែលថា អយ្យការអាចប្រកាសអំពីការផ្តន្ទាទោស គឺជាប្រភេទនៃប្រព័ន្ធច្បាប់រ៉ូម៉ាណូហ្សែម៉ានិក (Romano-Germanic)

---

[10] សំណើសុំរួម កថាខណ្ឌ២២ ដល់២៥។

[11] "ចម្លើយតបរបស់ក្រុមមេធាវីការពារ ទៅនឹងបញ្ជីឈ្មោះសាក្សី និងឯកសារទាំងឡាយដែលដាក់តម្កល់ដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១" ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ (ឯកសារលេខ E28/1) កថាខណ្ឌ៩-១៧។

[12] សំណើសុំរួម កថាខណ្ឌ៣២, ៣៣។

[13] ចម្លើយតបរបស់មេធាវីការពារក្តី កថាខណ្ឌ៥។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

00387086

E72/3



ដូចដែលបានគូសបញ្ជាក់ដោយសេចក្តីអធិប្បាយរបស់បារាំងស្តីពីច្បាប់ទាក់ទិននឹងដើមបណ្តឹងរដ្ឋប្បវេណី[14]។

## ខ. សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសួរសំណួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីទាក់ទិននឹងការផ្តន្ទាទោស

៨. សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានលើកសេចក្តីសន្និដ្ឋានថា មូលដ្ឋានច្បាប់ និងការអនុវត្តរបស់រដ្ឋផ្សេងៗទៀតដែលអនុវត្តប្រព័ន្ធដើមបណ្តឹងរដ្ឋប្បវេណី បានអនុញ្ញាតយ៉ាងច្បាស់ដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចោទសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ។ ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងបន្ថែមទៀតថា មិនអាចមានការអនុវត្តណាផ្សេងទៀតនោះទេ បើផ្អែកតាមការអនុវត្តពីមុនមករបស់អង្គជំនុំជម្រះសាលាដំបូងនោះ[15]។

៩. មេធាវីការពារបានលើកឡើងថា ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិក្នុងការដាក់សេចក្តីសន្និដ្ឋានទាក់ទិននឹងការផ្តន្ទាទោស ដូចនេះដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវអនុញ្ញាតឱ្យចោទសួរសំណួរទាក់ទងនឹងអត្តចរិតនោះទេ។ នៅក្នុងទស្សនៈរបស់មេធាវីការពារ ការផ្តោតការយកចិត្តទុកដាក់របស់ដើមបណ្តឹងរដ្ឋប្បវេណីគួរតែផ្តោតធ្វើទៅលើព្យសនកម្មដែលពួកគេទទួលរង។ មេធាវីការពារមិនបានប្រឆាំងនឹងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទិននឹងការសួរសំណួរអ្នកជំនាញនោះទេ[16]។

---

[14] ចម្លើយតបរបស់មេធាវីការពារក្តី កថាខណ្ឌ៥។

[15] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ទំព័រ៤៣ ដល់ ៤៩ (សហព្រះរាជអាជ្ញា) ទំព័រទី៤៩ ដល់ ៦៣ (ដើមបណ្តឹងរដ្ឋប្បវេណី)។

[16] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ទំព័រ ៦៣ ដល់ ៧៣។



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E C C C C E T C

## សំអាងហេតុ

## ក. សេចក្តីសម្រេចអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទិននឹងការផ្តន្ទាទោស

### ១. សាវតា

១០. តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីចំពោះមុខអ.វ.ត.ក ត្រូវតែយល់ដឹងនៅក្នុងបរិបទប្រវត្តិសាស្ត្រនៃការវិវឌ្ឍន៍របស់វា។ មាត្រា៣៦ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“ច្បាប់អ.វ.ត.ក”) ផ្តល់អំណាចឱ្យអង្គជំនុំជម្រះតុលាការកំពូល “[...] សម្រេចលើបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ជនរងគ្រោះ ឬសហព្រះរាជអាជ្ញា [...]”។ នៅពេលបទប្បញ្ញត្តិផ្សេងៗទៀតនៅក្នុងច្បាប់អ.វ.ត.ក យោងទៅលើជនរងគ្រោះ[17] ច្បាប់អ.វ.ត.ក មិនបានចែងអំពីការចូលរួមរបស់ជនរងគ្រោះ តាមមធ្យោបាយនៃនីតិវិធីដើមបណ្តឹងរដ្ឋប្បវេណី ថែមទាំងច្បាប់អ.វ.ត.ក ក៏មិនបានចែងអំពីយន្តការប្តឹងឧទ្ធរណ៍បន្ថែមនោះទេ ដោយអនុលោមតាមមាត្រា ៣៦ ថ្មី នៃច្បាប់អ.វ.ត.ក។

១១. ហេតុដូច្នេះ ច្បាប់បង្កើតអ.វ.ត.កនេះ បានទុកសិទ្ធិឱ្យអង្គជំនុំជម្រះវិសាមញ្ញនេះបកស្រាយអនុវត្តមាត្រា៣៦ថ្មីនេះ។ មាត្រា១២នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការចោទប្រកាន់តាមច្បាប់កម្ពុជា ចំពោះឧក្រិដ្ឋកម្មទាំងឡាយណាដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (“កិច្ចព្រមព្រៀង”) និងមាត្រា៣៣នៃច្បាប់អ.វ.ត.ក ចែងថា នីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រូវយកមកអនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអ.វ.ត.ក។ វិធានផ្ទៃក្នុងបានចែងអំពីប្រព័ន្ធដើមបណ្តឹងរដ្ឋប្បវេណី ដែលឆ្លុះបញ្ចាំងអំពីច្បាប់និងនីតិវិធីរបស់ប្រទេសកម្ពុជា និងដែលអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីស្វែងរកសំណងសមូហភាពនិងសំណង

---

[17] សូមមើលមាត្រា២៣នៃកិច្ចព្រមព្រៀង, មាត្រា២៣ថ្មី, ៣៣ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

ផ្លូវចិត្ត[18]។ ដើម្បីទទួលបាននូវសំណងបែបនេះ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះបទល្មើសដែលស្ថិតក្នុងយុត្តាធិការរបស់អ.វ.ត.ក តាមរយៈការគាំទ្រការចោទប្រកាន់[19]។ ដើម្បីយល់បានពេញលេញ វាជាការចាំបាច់ក្នុងការកត់សម្គាល់ថា កិច្ចព្រមព្រៀងក្តី ឬច្បាប់អ.វ.ត.កក្តី មិនបានអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចអំពីសំណងប្រឆាំងនឹងពិរុទ្ធជននោះទេ។

១២. គំរូដើមបណ្តឹងរដ្ឋប្បវេណីដែលចែងនៅក្នុងវិធានផ្ទៃក្នុងរបស់អ.វ.ត.ក គឺផ្អែកលើនីតិវិធីព្រហ្មទណ្ឌកម្ពុជា ប៉ុន្តែមិនដូចគ្នាសុទ្ធសាធទៅនឹងនីតិវិធីព្រហ្មទណ្ឌកម្ពុជានោះទេ[20]។ វាត្រូវតែមានលក្ខណៈស្របគ្នាជាមួយនឹងប្រភេទជាក់លាក់នៃដំណើរការនីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខអ.វ.ត.ក ពោលគឺការជំនុំជម្រះតែទៅលើបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋជាតិនិងអន្តរជាតិដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងប្រជាជនរាប់លាននាក់នៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ នៅក្នុងប្រទេសកម្ពុជា។ នៅក្នុងបរិបទនេះ លក្ខណៈនៃគំរូដើមបណ្តឹងរដ្ឋប្បវេណីតាមធម្មតា បង្កើតឡើងសម្រាប់ដំណើរការនីតិវិធីមិនស្មុគស្មាញ និងជនរងគ្រោះតិចតួច គឺតម្រូវឱ្យមានការកែសម្រួល។

១៣. ដោយសារតែច្បាប់បង្កើតអ.វ.ត.ក និងលក្ខណៈនៃដំណើរការនីតិវិធីព្រហ្មទណ្ឌមានការកំរិតដែលអង្គជំនុំជម្រះសាលាដំបូងត្រូវតែទទួលស្គាល់នោះ វាតម្រូវឱ្យមានការបកស្រាយក្នុងន័យចង្អៀតអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងនីតិវិធីចំពោះមុខអ.វ.ត.ក។

---

18 សូមមើលមាត្រា២១ ដល់មាត្រា២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

19 សូមមើលវិធាន២៣(១) នៃវិធានផ្ទៃក្នុង។

20 សំណងសមូហភាព និងផ្លូវចិត្ត មិនមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាទេ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

១៤. ដោយផ្អែកលើមូលដ្ឋាននេះ ឥឡូវ អង្គជំនុំជម្រះសាលាដំបូងពិនិត្យមើលអំពីការប្រព្រឹត្តទៅនៃសវនាការ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការប្តឹងសុំទាមទារសំណង និងតួនាទីរបស់ភាគីទាំងអស់ រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីចំពោះមុខអ.វ.ត.ក។

## ២. ការប្រព្រឹត្តិទៅនៃសវនាការ

១៥. ដូចនៅតាមយុត្តាធិការមួយចំនួនដែរ សវនាការនៅក្នុង អ.វ.ត.ក មិនត្រូវបានបែងចែកដំណាក់កាលនៃការជំនុំជម្រះ និងដំណាក់កាលផ្តន្ទាទោសដាច់ដោយឡែកពីគ្នាទេ[21]។ សក្ខីកម្ម និងភស្តុតាងដែលពាក់ព័ន្ធទាំងអស់ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ត្រូវបានយកមកពិភាក្សាដេញដោលនៅក្នុងអំឡុងពេលជំនុំជម្រះ ទោះបីជាសក្ខីកម្មនិងភស្តុតាងនោះពាក់ព័ន្ធនឹងបញ្ហាពិរុទ្ធភាព ឬគ្មានពិរុទ្ធភាព ឬការផ្តន្ទាទោសក៏ដោយ។

១៦. ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសវនាការនេះ ការលើកឡើងទាំងឡាយដែលមានបំណងគាំទ្រដល់ពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពរបស់ជនជាប់ចោទ ជាទូទៅ ត្រូវយកមកពិចារណានៅក្នុងអំឡុងដើមសប្តាហ៍នៃសវនាការ។ ទាំងនេះត្រូវបានបង្ហាញឡើងជាបន្តបន្ទាប់តាមគំរូនៃការរៀបចំ និងគំរូផ្សេងទៀត ដូចជាកម្មវត្ថុនៃបញ្ហាជាដើម ដើម្បីធានាដល់ការបង្ហាញអំពីភស្តុតាងដែលសមស្រប។ នាពេលនេះ សវនាការបានឈានដល់ដំណាក់កាលចុងក្រោយហើយ រីឯភស្តុតាងពាក់ព័ន្ធនឹងការផ្តន្ទាទោសកំពុងស្ថិតក្នុងការពិចារណាជាផ្នែកនៃការប្រព្រឹត្តិទៅនេះ។

---

[21] ការបែងចែកដំណាក់កាលសវនាការពាក់ព័ន្ធនឹងពិរុទ្ធភាព និងគ្មានពិរុទ្ធរបស់ជនជាប់ចោទម្ខាង និងម្ខាងទៀតពាក់ព័ន្ធនឹងបញ្ហានៃការផ្តន្ទាទោស (ក្នុងករណីដែលជនជាប់ចោទត្រូវបានរកឃើញថាមានទោស) ជាញឹកញាប់ត្រូវបានបែងចែកជាពីរផ្នែក។



អង្គជំនុំជម្រះសាលាដំបូង
TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C E T C

00387090



១៧. មិនថាការប្រព្រឹត្តិទៅបែបណាដែលតុលាការជ្រើសរើសធ្វើជាសវនាការមួយដែលប្រកបដោយយុត្តិធម៌និងប្រសិទ្ធភាពបំផុតនោះទេ វាមានលក្ខណៈសំខាន់ណាស់ក្នុងការបង្ហាញអំពីពិរុទ្ធភាពមុនពេលមានការផ្តន្ទាទោស ដូចនៅក្នុងរឿងក្តីនេះដូច្នោះដែរ សក្ខីកម្មទាំងអស់ដែលពាក់ព័ន្ធនឹងពិរុទ្ធភាព ឬក៏គ្មានពិរុទ្ធភាព និងការផ្តន្ទាទោសត្រូវបានពិភាក្សាដេញដោលដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសវនាការតែមួយ។ សាលក្រមនឹងមានទាំងភស្តុតាងនៃពិរុទ្ធភាព ឬគ្មានពិរុទ្ធភាព ហើយនឹងការផ្តន្ទាទោសប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធ។

## ៣. *សិទ្ធិរបស់ភាគីទាំងឡាយក្នុងការស្នើសុំសំណង នៅក្នុងពេលសវនាការបទល្មើសព្រហ្មទណ្ឌ*

១៨. នៅក្នុងយុត្តាធិការជាច្រើនដែលអនុវត្តតាមប្រព័ន្ធដើមបណ្តឹងរដ្ឋប្បវេណីរបស់បារាំង ជនរងគ្រោះមានសិទ្ធិចូលរួមនៅក្នុងសវនាការបទល្មើសព្រហ្មទណ្ឌ ដើម្បីផ្តល់នូវមធ្យោបាយបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពដើម្បីស្នើសុំនូវសំណងពីជនជាប់ចោទ។ ជាលទ្ធផល សវនាការមានគោលបំណងពីរយ៉ាង: មួយដើម្បីកំណត់សម្រេចពីពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពរបស់ជនជាប់ចោទ និងដើម្បីប្រកាសអំពីទោសនៅក្នុងករណីរកឃើញថាមានពិរុទ្ធភាព និងម្យ៉ាងទៀត ដើម្បីធានាសំណងតាមការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងករណីជនជាប់ចោទត្រូវបានផ្តន្ទាទោស។
ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("ក្រមឆ្នាំ ២០០៧") បានគិតគូរយ៉ាងច្បាស់លាស់អំពីលទ្ធភាពក្នុងការឱ្យមានកិច្ចដំណើរការនីតិវិធីចំនួនពីរ តែម្តងជាមួយគ្នា សម្រាប់ដំណើរការនីតិវិធីព្រហ្មទណ្ឌ និងមួយទៀត សម្រាប់ការទាមទារសំណងរដ្ឋប្បវេណី ។

## ៤. *តួនាទីរបស់ភាគីទាំងឡាយនៅក្នុងនីតិវិធីព្រហ្មទណ្ឌ*

### *ក) សហព្រះរាជអាជ្ញា*



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • E T C

១៩. មាត្រា៤ នៃក្រមឆ្នាំ២០០៧ ចែងថា៖
អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។

២០. អាជ្ញាធរអយ្យការ ក៏តំណាងឱ្យ "ផលប្រយោជន៍យុត្តិធម៌" និងមានតួនាទីអនុវត្តបណ្តឹងអាជ្ញា នៅក្នុង "ផលប្រយោជន៍ទូទៅរបស់សង្គម"[22]។ ផលប្រយោជន៍របស់សង្គមទាំងមូល និងផលប្រយោជន៍យុត្តិធម៌ គឺរួមបញ្ចូលទាំងផលប្រយោជន៍ជាទូទៅរបស់ជនរងគ្រោះនៃបទល្មើសដែលត្រូវចោទប្រកាន់ជាចាំបាច់។ យោងតាមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា អំណាចអាជ្ញាក៏ត្រូវជួយក្នុងការស្វែងរកការបង្ហាញការពិត និងត្រូវចោទប្រកាន់ដោយមិនលម្អៀង ដោយពិចារណានូវអង្គហេតុ និងកាលៈទេសៈដែលពាក់ព័ន្ធទាំងអស់។

២១. ដូចដែលមាននៅក្នុងយុត្តាធិការភាគច្រើនគឺថា តួនាទីរបស់អយ្យការ រួមមានភារកិច្ចក្នុងការជួយតុលាការឱ្យស្វែងរកបាននូវការពិត និងបំរើផលប្រយោជន៍យុត្តិធម៌ពាក់ព័ន្ធទាំងសហគមន៍ ទាំងជនជាប់ចោទ អនុលោមតាមច្បាប់ និងវិធានយុត្តិធម៌។ ព្រះរាជអាជ្ញាតំណាងឱ្យសហគមន៍ មិនមែនតំណាងឱ្យបុគ្គល ឬផលប្រយោជន៍ផ្នែកណាមួយនោះទេ ដូចជាផលប្រយោជន៍ដែលពាក់ព័ន្ធនឹងការទាមទារសំណងជាដើម។

២២. តាមន័យនេះ សហព្រះរាជអាជ្ញាមានតួនាទីជាអ្នកតំណាងឱ្យផលប្រយោជន៍សាធារណៈដើម្បីជួយតុលាការក្នុងការស្វែងរកនូវការផ្តន្ទាទោសឱ្យបានសមស្រប ដែលថ្លឹងថ្លែងនូវផលប្រយោជន៍របស់សហគមន៍ ភាពធ្ងន់ធ្ងរនៃបទល្មើស។ បន្ទាប់មកទៀត រួមបញ្ចូលទាំងធាតុផ្សំនៃការដាក់ទណ្ឌកម្ម និង

[22] មាត្រា៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា *សូមមើលបន្ថែម* មាត្រា៣៣៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ (ចែងថា ព្រះរាជអាជ្ញាធ្វើការសន្និដ្ឋានប្តឹងសុំដោយផ្ទាល់មាត់ដែលខ្លួនយល់ឃើញថា "សមស្របទៅនឹងប្រយោជន៍នៃយុត្តិធម៌")។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • E C T C

ការធ្វើឱ្យញញើត ព្រមទាំងពិចារណាអំពីលទ្ធភាពនៃការស្តារនីតិសម្បទាផងដែរ។ កត្តាទាំងអស់នេះត្រូវបានថ្លឹងថ្លែងជាមួយនឹងបញ្ហានៃភាពយុត្តិធម៌ និងផលប្រយោជន៍យុត្តិធម៌ជាទូទៅ។

២៣. អយ្យការ ដែលមិនមានផលប្រយោជន៍នៅក្នុងបណ្តឹងរដ្ឋប្បវេណីជាលក្ខណៈបុគ្គលនោះ តាមធម្មតា មិនអាចជ្រៀតជ្រែកក្នុងបណ្តឹងរដ្ឋប្បវេណីដែលបានផ្អែកលើនីតិវិធីតទល់គ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទ និងដែលដាក់ស្របគ្នានឹងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌបានទេ។

### *ខ) មេធាវីការពារ*

២៤. តួនាទីរបស់មេធាវីការពារ គឺដើម្បីការពារឱ្យជនជាប់ចោទនៅគ្រប់ដំណាក់កាលនៃការជំនុំជម្រះរួមទាំងការផ្តន្ទាទោសផង។ មេធាវីការពារក៏មានតួនាទីជួយធានាឱ្យមានការជំនុំជម្រះដោយយុត្តិធម៌ដល់ជនជាប់ចោទ និងជួយតុលាការក្នុងការស្វែងរកការពិត។

### *គ) ដើមបណ្តឹងរដ្ឋប្បវេណី*

២៥. តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីចំពោះមុខអ.វ.ត.ក គឺអនុលោមតាមវិធាន ២៣(១) "ដើម្បីចូលរួមក្នុងដំណើរការនីតិវិធី [...] ដោយគាំទ្រដល់ការចោទប្រកាន់"។ មូលហេតុច្បាស់លាស់នៃសិទ្ធិក្នុងការចូលរួម គឺថា វាជាផលប្រយោជន៍ទាំងសហគមន៍កម្ពុជាដែលតំណាងដោយសហព្រះរាជអាជ្ញា និងផលប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលការផ្តន្ទាទោសចំពោះបទល្មើសព្រហ្មទណ្ឌដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ។ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិស្វែងរកសំណងតាមការផ្តន្ទាទោសជនជាប់ចោទនោះ។ ដូចដែលបានកត់សម្គាល់ពីមុនមក បទប្បញ្ញត្តិត្រូវតែបកស្រាយក្នុងន័យចង្អៀត និងមិនផ្តល់សិទ្ធិទូទៅនៃការចូលរួមស្មើភាពគ្នាជាមួយសហព្រះរាជអាជ្ញានោះទេ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • C E T C

២៦. នៅក្នុងការជំនុំជម្រះម្តងហើយម្តងទៀត មេធាវីការពារបានលើកឡើងអំពីបញ្ហានៃសមភាពអំណាចជាមួយនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿងលេខ០០១ ដែលមានចំនួនសរុប៩៣ នាក់ បច្ចុប្បន្ននៅសល់ចំនួន៩០នាក់។ អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា នេះជាបញ្ហាដែលអាចប៉ះពាល់ដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នៅក្នុងដំណើការនីតិវិធីព្រហ្មទណ្ឌរួមមានទាំងសិទ្ធិប្រឈមមុខទៅនឹងអាជ្ញាធរចោទប្រកាន់តែមួយប៉ុណ្ណោះ។ ដូច្នេះហើយ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិគាំទ្រ ឬជួយដល់អយ្យការ ដូចដែលកំពុងអនុវត្តនេះ តួនាទីរបស់ពួកគេនៅក្នុងការជំនុំជម្រះក្តីនេះ មិនត្រូវប្រែក្លាយទៅជាព្រះរាជអាជ្ញាបន្ថែមទៀតបានទេ។

២៧. ភាគីនីមួយៗមានតួនាទីខុសៗគ្នានៅក្នុងការរក្សាផលប្រយោជន៍ និងការទទួលខុសត្រូវជាពិសេសរបស់ខ្លួននៅក្នុងការជំនុំជម្រះក្តី។

***៥. តើដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិផ្តល់មតិយោបល់លើការផ្តន្ទាទោសនៅក្នុងសារណា និងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ពួកគាត់ដែរឬទេ?***

២៨. ក្នុងការសម្រេចថា តើវិសាលភាពនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខអ.វ.ត.ក អនុញ្ញាតឱ្យដាក់សេចក្តីសន្និដ្ឋាននិងលើកអំណះអំណាងទាក់ទិននឹងការផ្តន្ទាទោសឬយ៉ាងណានោះ ជាដំបូង អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា វិធានផ្ទៃក្នុងរបស់អ.វ.ត.កមិនមានចែងច្បាស់អំពីសិទ្ធិ ឬការកំរិតសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការផ្តន្ទាទោសទេ។ ទោះជាយ៉ាងនេះក្តី វិធាន ១០៥(១)(ឃ)នៃវិធានផ្ទៃក្នុង កំណត់អំពីសិទ្ធិនៃការប្តឹងឧទ្ធរណ៍នៅក្នុងករណីដែលពាក់ព័ន្ធនឹង "ផលប្រយោជន៍រដ្ឋប្បវេណីដ៏ទៃទៀតរបស់ពួកគេ" តែប៉ុណ្ណោះ។

២៩. ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ចែងអំពីផ្នែកមួយចំនួននៃនីតិវិធីព្រហ្មទណ្ឌដែលដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួម[23]។ មុនឆ្នាំ២០០៧ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ អនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីនូវសិទ្ធិពេញលេញនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ប៉ុន្តែ ក្រោយអនុម័តក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ អង្គការនីតិបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា បានកំរិតនូវសិទ្ធិទាំងនេះ[24]។ បច្ចុប្បន្ននេះ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈចង្អៀតដោយផ្តោតទៅលើតែផលប្រយោជន៍សំណងរដ្ឋប្បវេណីរបស់ពួកគេប៉ុណ្ណោះ។ គេអាចធ្វើសេចក្តីសន្និដ្ឋានថា វិធាន១០៥(១)(ឃ)នៃវិធានផ្ទៃក្នុង ដែលឆ្លុះបញ្ចាំងមាត្រា៣៧៥នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ត្រូវតែយល់ឃើញអោយស្របគ្នាទៅនឹងមាត្រានេះ។

៣០. លើសពីនេះទៀត ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧នេះ ក៏បានលើកឡើងនូវគោលការណ៍សំខាន់ជាក់ស្តែងដែលបែងចែកយ៉ាងច្បាស់រវាងបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី។ មាត្រា២ ចែងថា៖

> បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីគឺជាបណ្តឹងពីរផ្សេងគ្នា។
>
> បណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់។

---

[23] ក្នុងចំណោមមាត្រាផ្សេងទៀត សូមមើលមាត្រា៣៣៤ និងមាត្រា៣៣៥នៃក្រមឆ្នាំ២០០៧។

[24] សូមមើល មាត្រា១៦១ និង១៧០នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. E.T.C.

បណ្ដឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឱ្យបានជួសជុលការខូចខាតដែលបណ្ដាលមកពីអំពើល្មើស ដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មមនឹង ព្យសនកម្មដែលខ្លួនបានទទួល។

៣១. ទោះជាមានការកែប្រែបែបផែននៃបណ្ដឹងឧទ្ធរណ៍នាពេលថ្មីៗនេះក៏ដោយ ក៏គោលការណ៍ ទាំងនេះ គឺជាមូលដ្ឋាននៃការប្រែប្រួលនៅក្នុងការអនុវត្តច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលផ្ដោតយ៉ាង ច្បាស់ទៅលើភាពខុសគ្នានៃបណ្ដឹង និងសិទ្ធិរបស់ភាគីនានា។

៣២. វិធាន២៣(១)(ក) ដែលចែងអំពីសិទ្ធិគាំទ្រដល់ការចោទប្រកាន់ហាក់មិនកំណត់នោះ ត្រូវតែ ចែងដោយផ្អែកទៅលើគោលការណ៍ពីរយ៉ាង:

៣៣. ទីមួយ ផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីមានន័យថាត្រូវតែស្វែងរកសំណង។ ទោះជា យ៉ាងនេះក្ដី តម្រូវការបឋមសម្រាប់សំណង គឺការរកឃើញពិរុទ្ធភាព។ ដូច្នេះ ដើមបណ្ដឹង រដ្ឋប្បវេណី ក៏មានផលប្រយោជន៍ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងកំណត់បានធាតុផ្សំនៃបទល្មើស នៅ ពេលដែលមានភស្តុតាងបញ្ជាក់ ដែលបង្កើតបានជាមូលដ្ឋានសម្រាប់បណ្ដឹងរដ្ឋប្បវេណីទាមទារសំណងរបស់ ខ្លួន។ ចំពោះហេតុផលនេះ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានផ្ដល់សិទ្ធិឱ្យគាំទ្រដល់អយ្យការក្នុងការកំណត់ បានធាតុផ្សំនូវបទល្មើសព្រហ្មទណ្ឌទៅលើជនជាប់ចោទដែលមានឥទ្ធិពលទៅលើដើមបណ្ដឹងរដ្ឋប្ប វេណី និងបង្កើតជាមូលដ្ឋានសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីទាមទារសំណង។

៣៤. ទីពីរ គោលបំណងទាំងមូលនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា គឺផ្ដល់ការពិត។ ភាគីទាំងអស់អាចជួយ ឱ្យបានសម្រេចគោលបំណងនេះ[25]។ ដោយមានផលប្រយោជន៍ជាមូលដ្ឋានដើម្បីទទួលបានសំណង ចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ការផ្ដល់ការពិត គឺកំណត់ចំពោះអង្គហេតុ ឬកត្តានានាដែលទាក់ទង

---

[25] សូមអានមាត្រា៣៣៤នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។



ECCC TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

ទៅនឹងការកំណត់ពិរុទ្ធភាព ឬគ្មានពិរុទ្ធនៃជនជាប់ចោទ។ គោលការណ៍នេះមានប្រសិទ្ធភាព ទោះជាដើមបណ្ដឹងរដ្ឋប្បវេណីមិនមែនជាជនរងគ្រោះនៃបទល្មើសដោយផ្ទាល់ក៏ដោយ តែក៏ជាជនរងគ្រោះនៃអំពើល្មើសដែរ[26]។ ដើមបណ្ដឹងរដ្ឋប្បវេណីបែបនេះមិនអាចផ្ដល់ការពិតដោយផ្ដល់ព័ត៌មានដោយផ្ទាល់ដែលទាក់ទងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទេ។ ទោះជាយ៉ាងនេះក្ដី ពួកគេអាចមានព័ត៌មានជាមូលដ្ឋានដែលជួយដល់ការស្វែងរកការពិតផងដែរ។

៣៥. ដូចដែលបានលើកឡើងនៅក្នុងសំណើរួមដូច្នេះដែរ គឺវិធាន២៣(១)(ក) នៃវិធានផ្ទៃក្នុង មិនបានចែងអំពីមូលដ្ឋានច្បាប់សម្រាប់សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្ដីសន្និដ្ឋានអំពីការផ្ដន្ទាទោសទេ។

៣៦. ទីបញ្ចប់ ដូចដែលបានកត់សម្គាល់ពីមុនមក ដំណើរការនីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខ អ.វ.ត.ក មិនបានបែងចែកការជំនុំជម្រះជាពីរដំណាក់កាល និងការផ្ដន្ទាទោសនោះទេ។ ដូច្នេះ ភស្តុតាងដែលទាក់ទងនឹងការចោទប្រកាន់ ការផ្ដន្ទាទោស និងសំណង គឺបង្កើតឡើងដំណាលគ្នា ដែលជួនកាលមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងគោលបំណងនៃភស្តុតាង ជាពិសេស ក្នុងពេលស្របគ្នានេះ រវាងអង្គហេតុទាក់ទងទៅនឹងការចោទប្រកាន់ និងការផ្ដន្ទាទោស។ ប៉ុន្តែ ភាពមិនច្បាស់លាស់នេះមិនបានអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីវាយតម្លៃអង្គហេតុទាំងអស់ដែលកើតមាននៅក្នុងរឿងក្ដីព្រហ្មទណ្ឌបានទេ។ ការវាយតម្លៃអង្គហេតុបែបនេះរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមានកម្រិតក្នុងការជួយដល់សហព្រះរាជអាជ្ញាដើម្បីដាក់ពិរុទ្ធភាព ឬមិនដាក់ពិរុទ្ធភាពដល់ជនជាប់ចោទ និងចំណាត់ការសំណង។ បើអង្គហេតុទាក់ទងតែទៅនឹងការផ្ដន្ទាទោសនោះ ដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចវាយតម្លៃអង្គហេតុបែបនេះ ឬក៏ធ្វើសេចក្ដីសន្និដ្ឋានបានទេដែលទាក់ទងនឹងរឿងនេះ។

---

[26] សំណើរួម កថាខណ្ឌ២២ដល់២៥



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

00387097

E72/3



៣៧. មាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលអនុញ្ញាតឲ្យមានការយោងដល់ "ច្បាប់ដែលត្រូវបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ" នោះ មិនអនុញ្ញាតអោយមានការយល់ផ្សេងពីនេះអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលទាក់ទងទៅនឹងការផ្តន្ទាទោសនោះទេ។ មិនមានភាពមិនច្បាស់លាស់នៅក្នុងការបកស្រាយវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលអាចឈានទៅដល់ការបកស្រាយថាជាការផ្តល់សិទ្ធិដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសនោះក៏ទេដែរ។ ទោះជាមានការផ្តល់សិទ្ធិបែបនេះក៏ដោយចុះ ក៏ប្រព័ន្ធច្បាប់ Romano-Germanic ដែលឱ្យជនរងគ្រោះធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ឬឱ្យគាំទ្រដល់ការចោទប្រកាន់ មិនអាចត្រូវបានចាត់ទុកថាជា "វិធានដែលត្រូវបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិនោះទេ"។ ជាងនេះទៅទៀត វិធានដែលទាក់ទងនឹងតួនាទីរៀងៗខ្លួនរវាងអយ្យការ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានបង្កើតឡើងក្នុងកម្រិតជាតិ គឺមានលក្ខណៈមិនដូចគ្នាពីរដ្ឋមួយទៅរដ្ឋមួយឡើយ។

៣៨. មតិភាគច្រើនរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងទទួលយកសេចក្តីសន្និដ្ឋាន ដែលបានធ្វើនៅក្នុងសំណើរួមដែលថា យុត្តិសាស្ត្ររបស់បារាំងបានអនុញ្ញាតអោយមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការផ្តន្ទាទោសនោះ គឺមិនមានតម្លៃជាសកលនោះទេ ហើយនៅទីនេះ អ.វ.ត.ក ត្រូវបានតម្រូវឱ្យផ្អែកលើច្បាប់ និងនីតិវិធីរបស់ខ្លួនតាមច្បាប់កម្ពុជា ឬបទដ្ឋានដែលបង្កើតឡើងក្នុងកំរិតអន្តរជាតិ[27]។ មតិភាគច្រើនរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងកត់សំគាល់បន្ថែមទៀតថា មានតែតុលាការព្រហ្មទណ្ឌកម្រិតអន្តរជាតិទេដែលចែងឲ្យមានការចូលរួមរបស់ជនរងគ្រោះ គឺតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC")។ ទោះជាយ៉ាងនេះក្តី តាមគម្រោងការណ៍ ដែលបង្កើតឡើងដោយលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ មិនមានភាពទាក់ទងចាំបាច់រវាងការចូលរួមរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ និងការចូលរួមរបស់ជនរងគ្រោះទាក់ទងទៅនឹងសំណង

---

[27] សូមអានផងដែរ"ចម្លើយតបរបស់ក្រុមមេធាវីការពារ ទៅនឹងបញ្ជីឈ្មោះសាក្សី និងឯកសារទាំងឡាយដែលដាក់តម្កល់ដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១" ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ (ឯកសារលេខ E28/1) កថាខណ្ឌ៩-១៧។

ទេ។ បណ្តឹងរដ្ឋប្បវេណី មិនមែនជាតម្រូវការជាមុនសម្រាប់ជនរងគ្រោះដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនៅចំពោះតុលាការឧក្រិដ្ឋកម្មអន្តរជាតិទេ។

៣៩. មាត្រា៦៨(៣) នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ចែងឱ្យមានការចូលរួមប្រសិនជាជនរងគ្រោះមានការប៉ះពាល់ដល់ "ផលប្រយោជន៍ផ្ទាល់ខ្លួន"។ ដូច្នេះ ជនរងគ្រោះដែលចូលរួមក្នុងកិច្ចដំណើការនីតិវិធីចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ មិនមែនជា "ដើមបណ្តឹងរដ្ឋប្បវេណីទេ" និងមិនមានការណែនាំណានៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមដែលចែងពីសិទ្ធិពិសេសរបស់ "ដើមបណ្តឹងរដ្ឋប្បវេណី" ឡើយ។ លើសពីនេះទៀត យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិដែលមានកន្លងមក បានកំរិតសិទ្ធិរបស់ជនរងគ្រោះយ៉ាងតឹងរ៉ឹងក្នុងការបញ្ចេញទស្សនៈរបស់ខ្លួន នៅក្នុងអំឡុងពេលជំនុំជម្រះ[28]។

៤០. ហេតុដូច្នេះហើយ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើសេចក្តីសន្និដ្ឋាន ឬផ្តល់អនុសាសន៍ដែលជាប់ទាក់ទងទៅនឹងការផ្តន្ទាទោស ដែលរួមមានសេចក្តីសន្និដ្ឋានអំពីអង្គច្បាប់ទៅលើការផ្តន្ទាទោស ឬការវាយតម្លៃអង្គហេតុ ឬកត្តាផ្សេងៗដែលទាក់ទងទៅនឹងការផ្តន្ទាទោសនោះ។

## *ខ.* *សេចក្តីសង្ខេប*

៤១. ហេតុដូច្នេះហើយបានជាអង្គជំនុំជម្រះសាលាដំបូងសង្កេតឃើញថា ភាគីនីមួយៗនៃកិច្ចដំណើរការនីតិវិធីចំពោះមុខ អ.វ.ត.ក មានតួនាទីផ្សេងៗគ្នា។ សម្រាប់សហព្រះរាជអាជ្ញា គឺត្រូវបង្ហាញ

[28] *សូមអាន រឿងក្តី រដ្ឋអាជ្ញាទល់នឹង* *Lubanga Dyilo* "បណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា និងមេធាវីការពារទៅលើសេចក្តីសម្រេចដែលមានក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការចូលរួមរបស់ជនរងគ្រោះថ្ងៃទី១៨ ខែមករា ឆ្នាំ ២០០៨" ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨ (ICC-01/04-01/06-1432) កថាខណ្ឌ១០៤ សាលក្រមមតិភាគច្រើនជាមួយនិងមតិជំទាស់ពីរ ដែលមិនអនុញ្ញាតឱ្យជនរងគ្រោះបង្ហាញភស្តុតាងចំពោះពិរុទ្ធភាព និងភាពគ្មានពិរុទ្ធ។

ពិរុទ្ធភាពជនជាប់ចោទ[29] ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណីវិញ ដែលមានផលប្រយោជន៍ក្នុងការស្វែងរកសំណង តាមរយៈសេចក្តីសម្រេចអំពីបណ្តឹងចំពោះបទឧក្រិដ្ឋទៅលើជនជាប់ចោទនោះ មានសិទ្ធិដើម្បីជួយដល់អយ្យការក្នុងការផ្តល់ការពិតក្នុងអំឡុងពេលសវនាការ។

៤២. ទោះបីជាយ៉ាងណាក៏ដោយ ទាក់ទងទៅនឹងការផ្តន្ទាទោស តួនាទីដែលបានរៀបរាប់ខាងលើគឺញែកដាច់ពីគ្នា។ ការទទួលខុសត្រូវរបស់សហព្រះរាជអាជ្ញា គឺធានាឱ្យមានការផ្តន្ទាទោសសមស្រប រីឯការទទួលខុសត្រូវរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺទាមទារសំណង ដូចដែលមានចែងក្នុងវិធានផ្ទៃក្នុងរបស់អ.វ.ត.ក។ ព្រះរាជអាជ្ញាមិនមានតួនាទីក្នុងការទាមទារសំណងទេ រីឯដើមបណ្តឹងរដ្ឋប្បវេណីមិនមានតួនាទីពាក់ព័ន្ធនឹងការផ្តន្ទាទោសនោះដែរ។ បន្ទាប់មកទៀត ការការពារផលប្រយោជន៍សាធារណៈទូទៅ និងការការពារផលប្រយោជន៍ផ្នែកយុត្តិធម៌ គឺជាតួនាទីផ្តាច់មុខរបស់អយ្យការ។ ពាក់ព័ន្ធនឹងដំណាក់កាលពីរនៃសវនាការ ដែលមិនចែកដាច់ពីគ្នា និងដែលដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងសវនាការព្រហ្មទណ្ឌនោះ មិនបង្កើតអោយមានចំណុចចាប់ផ្តើមនៃសិទ្ធិដែលឃ្លាតចាកពីគោលការណ៍ចម្បងនេះទេ។

៤៣. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនេះ ធ្វើឡើងដោយមតិភាគច្រើន ដោយអនុលោមតាមមាត្រា ១៤(១)(ក)ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ចៅក្រម Jean-Marc Lavergne បន្ថែមមតិជំទាស់ខ្លះ។

## ខ. <u>សេចក្តីណែនាំស្តីពីការតាំងសំណួរដល់ជនជាប់ចោទ អ្នកជំនាញ និងសាក្សី ដោយដើមបណ្តឹងរដ្ឋប្បវេណីស្តីពីអត្តចរិតជនជាប់ចោទ</u>

---

[29] សូមមើលវិធាន៨៧(១) នៃវិធានផ្ទៃក្នុង។

៤៤. ដោយបានដឹងថា ដើមបណ្តឹងរដ្ឋប្បវេណីអាចវាយតម្លៃភស្តុតាង ដែលបានបង្កើតឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលជាប់ទាក់ទងតែនឹងការកំណត់ពិរុទ្ធភាព ឬគ្មានពិរុទ្ធរបស់ជនជាប់ចោទ និងដើម្បីគាំទ្រដល់ការទាមទារសំណងរបស់ពួកគេនោះ ឥឡូវនេះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែកំណត់ថាតើដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានហាមឃាត់មិនឱ្យសួរជនជាប់ចោទ ឬសាក្សីនានាពាក់ព័ន្ធនឹងអត្តចរិតជនជាប់ចោទដែរឬទេ។

៤៥. អត្ថន័យពាក្យ "អត្តចរិត" រួមមាន បុគ្គលិកលក្ខណៈ និស្ស័យ សុចរិតធម៌ និងកេរ្តិ៍ឈ្មោះរបស់បុគ្គល។ លើកលែងតែពុំមានភស្តុតាងច្បាស់លាស់អំពីអសមត្ថភាពផ្នែកសតិ ដែលអាចមានឥទ្ធិពលទៅលើអំពើរបស់ជនជាប់ចោទ ឬសមត្ថភាពរបស់គាត់ដើម្បីបង្កើតបានជាចេតនាដែលចាំបាច់ត្រូវទទួលការផ្តន្ទាទោសចំពោះបទល្មើសនោះ។ គ្មានធាតុណាមួយក្នុងចំណោមធាតុទាំងនេះជាប់ទាក់ទងទៅនឹងការស៊ើបសួរចំពោះពិរុទ្ធភាព ឬ គ្មានពិរុទ្ធភាពរបស់ជនជាប់ចោទនោះឡើយ។

៤៦. នៅក្នុងសំណុំរឿងនេះ ផ្នែកនៃការពិភាក្សាដេញដោលដែលធ្វើឡើងដូចដែលបានចែងនៅក្នុងដីកាកំណត់កាលវិភាគថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ ស្តីពី "ការសាកសួរសាក្សី និងអ្នកជំនាញស្តីពីបញ្ហាទាក់ទងទៅនឹងអត្តចរិតរបស់ជនជាប់ចោទ" ទាក់ទងតែទៅនឹងបញ្ហាអត្តចរិត និងបុគ្គលភាពរបស់ជនជាប់ចោទតែប៉ុណ្ណោះ។ នេះគឺជាការពិនិត្យដើម្បីកំណត់អំពីស្ថានទម្ងន់ ឬស្ថានសម្រាលទោសពាក់ព័ន្ធនឹងការផ្តន្ទាទោសណាមួយដែលមានជាបន្តបន្ទាប់ និងមិនទាក់ទងនឹងពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទឡើយ[30]។ គោលបំណងតែមួយនៃភស្តុតាងនេះ គឺដើម្បីធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បញ្ហាដែលទាក់ទងទៅនឹងការផ្តន្ទាទោស ប្រសិនបើមាន។

---

[30] សូមអានផងដែរមាត្រា៧៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម និងវិធាន១៤៥នៃវិធាននីតិវិធីនិងភស្តុតាងរបស់ ICC។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • E T C

៤៧. ហេតុដូច្នេះហើយបានជាមតិភាគច្រើនរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ការសាកសួរអំពីអត្តចរិត ជនជាប់ចោទ ឬសាក្សីដែលបានកោះហៅមកផ្តល់សក្ខីកម្មអំពីអត្តចរិតរបស់គាត់ គឺជាប់ទាក់ទងតែទៅនឹងការផ្តន្ទាទោសមួយមុខតែប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា សាក្សី និងអ្នកជំនាញមួយចំនួន ដែលត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្មនឹងលើកឡើងនូវបញ្ហាដែលផ្តោតទៅលើសំណង ដូចជាលទ្ធភាពនៃការផ្សះផ្សាជាមួយជនរងគ្រោះនិង/ឬដើមបណ្តឹងរដ្ឋប្បវេណី។

៤៨. ហេតុដូច្នេះហើយអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណីជាទូទៅមិនអាចសាកសួរជនជាប់ចោទដែលទាក់ទងទៅនឹងអត្តចរិតរបស់គាត់បានទេ។ អង្គជំនុំជម្រះសាលាដំបូងក៏បានសម្រេចផងដែរថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចសាកសួរអ្នកជំនាញ និងសាក្សីដូចខាងក្រោមដែលនឹងផ្តល់សក្ខីកម្មតែអំពីអត្តអត្តចរិតជនជាប់ចោទ: KW-34 និង Francoise Seroni-Guilbaud, D1, D2, D3, D4, D5, D6 Christopher Lapel, D8 និង D14។ សាក្សី D8 និង D14 ត្រូវបានមេធាវីការពារសម្រេចដកចេញវិញ ហើយអង្គជំនុំជម្រះសាលាដំបូងមិនបានកោះហៅសាក្សីទាំងពីររូបនេះមកផ្តល់សក្ខីកម្មទេ។

៤៩. នេះគឺជាសេចក្តីសម្រេចដោយមតិភាគច្រើន ដូចដែលមានចែងដោយមាត្រា១៤(១)(ក) ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ចៅក្រម Jean-Marc Lavergne បន្ថែមមតិជំទាស់។ JM NWR

ភ្នំពេញ ថ្ងៃទី 0៩ ខែតុលា ឆ្នាំ២00៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល - ណុន**

# មតិជំទាស់របស់ចៅក្រម LAVERGNE
# ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង

## សេចក្តីផ្តើម

១. កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា[1] ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[2] បានបង្កើតឲ្យមានប្រព័ន្ធតុលាការដែលមានលក្ខណៈពិសេសដោយឡែកមួយ។ ព្រោះថា អង្គជំនុំជម្រះវិសាមញ្ញ គឺជាសាលាជម្រះក្តីដែលមានលក្ខណៈជាតិផង និងអន្តរជាតិផង។ អង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានបង្កើតឡើងក្នុងប្រព័ន្ធតុលាការកម្ពុជា ហើយទទ្ទឹមគ្នាផងដែរ អង្គជំនុំជម្រះនេះ គឺជាសាលាជម្រះក្តីឯករាជ្យ និងដាច់ដោយឡែកមួយ ពោលគឺមិនចំណុះទៅនឹងសាលាជម្រះក្តីថ្នាក់ជាតិណាមួយឡើយ។ អង្គជំនុំជម្រះវិសាមញ្ញ មានយន្តការនៃការប្រព្រឹត្តទៅរបស់ខ្លួនផ្ទាល់ទៅតាមលក្ខន្តិកៈដែលបានកំណត់ ហើយមានសមត្ថកិច្ចផ្តាច់មុខជំនុំជម្រះតែទៅលើរឿងក្តីដែលត្រូវបានកំណត់ច្បាស់លាស់ពាក់ព័ន្ធទៅនឹងបុគ្គលមួយចំនួនដែលត្រូវចោទប្រកាន់ពីបទល្មើសជាក់លាក់ ហើយដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលកំណត់មួយ។[3] អង្គជំនុំជម្រះវិសាមញ្ញ បានបង្ហាញនូវលក្ខណៈពិសេសរបស់ខ្លួនមួយ

---

[1] "កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិឡើងនៅក្នុងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ" ដែលអំណោះតទៅ ហៅថា "កិច្ចព្រមព្រៀង" ដែលបានចូលជាធរមានកាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥។ ឯកសារអង្គការសហប្រជាជាតិ លេខ A/RES/57/228B (Annexe)។

[2] អំណោះតទៅហៅថា "អង្គជំនុំជម្រះវិសាមញ្ញ"។

[3] "សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៨ (ឯកសារ E39/5) កថាខណ្ឌទី១០។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • C E T C

E72/3



ប្រសិនណាជាយើងប្រៀបធៀបទៅនឹងសាលាជម្រះក្តីអន្តរជាតិដទៃទៀត ត្រង់លក្ខណៈពិសេសនៃវិធានដែលអនុវត្តចំពោះការចូលរួមរបស់ជនរងគ្រោះទៅក្នុងនីតិវិធី។

២. ជាក់ស្តែង ច្បាប់ស្តីពីការបង្កើត អង្គជំនុំជម្រះវិសាមញ្ញ មិនថាច្បាប់ដែលបានធ្វើកាលពីឆ្នាំ ២០០១ ដែលកិច្ចព្រមព្រៀងបានយោងទៅដល់ ឬច្បាប់ដែលបានធ្វើកាលពីឆ្នាំ ២០០៤ ទេ ច្បាប់នោះបានចែងយ៉ាងច្បាស់ថា ជនរងគ្រោះមានសិទ្ធិចូលរួមទៅក្នុងនីតិវិធីដែលបានដាក់ឱ្យអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ មាត្រា៣៦ នៃច្បាប់នេះបានអនុញ្ញាតិឱ្យ "ជនរងគ្រោះ" មានសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[4]។ លទ្ធភាពក្នុងការប្តឹងឧទ្ធរណ៍នេះអាចធ្វើទៅបានដរាបណាជនរងគ្រោះទាំងនេះជាភាគីនៃរឿងក្តី។ ដើម្បីកំណត់ថាតើគំរូនៃនីតិវិធីបែបណាដែលគេត្រូវយោងទៅដល់ ដើម្បីអនុញ្ញាតិឱ្យមានការចូលរួមរបស់ជនរងគ្រោះទៅក្នុងនីតិវិធីនៃរឿងក្តី គេត្រូវពិនិត្យមើលជាបឋម ដោយយោងទៅលើបទបញ្ញត្តិនៃមាត្រា ១២ នៃកិច្ចព្រមព្រៀង នូវគំរូនីតិវិធីដែលមានចែងនៅក្នុងច្បាប់របស់កម្ពុជា។ គំរូនីតិវិធីមួយនេះនឹងអនុញ្ញាតិអោយជនរងគ្រោះដែលបានដាក់ពាក្យបណ្តឹង អាចចូលរួមក្នុងដំណើរការនីតិវិធីក្នុងឋានៈជា "ដើមបណ្តឹងរដ្ឋប្បវេណី" ក្នុងលក្ខខណ្ឌដែលជនរងគ្រោះទាំងនោះបង្ហាញថាខ្លួនបានទទួលរងនូវព្យសនកម្មដោយផ្ទាល់ពីអំពើទាំងឡាយដែលបានកំណត់នៅក្នុងបទចោទប្រកាន់[5]។ ម្យ៉ាងទៀត ការយោងទៅលើច្បាប់របស់កម្ពុជានេះមានលក្ខណៈរឹតត្បិត ពីព្រោះវិធាននីតិវិធីរបស់កម្ពុជានឹងអាចយកមកអនុវត្តបានដរាបណាវិធានទាំងអស់នោះមិនផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិ[6]។

[4] អំណេះតទៅ ហៅថា "អង្គជំនុំជម្រះ" ឬ "អង្គជំនុំជម្រះសាលាដំបូង"។

[5] សូមពិនិត្យមើលមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (អំណេះតទៅ ហៅថា "ក្រមឆ្នាំ ២០០៧") និងវិធាន ២៣ ២) នៃវិធានផ្ទៃក្នុង។

[6] មាត្រា ១២-១ នៃកិច្ចព្រមព្រៀងបានចែងថា "នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា" ក៏ប៉ុន្តែ កិច្ចព្រមព្រៀងក៏បានចែងផងដែរថា ប្រសិនណាច្បាប់របស់កម្ពុជា "មិនបានចែងចំពោះករណីពិសេស ឬក្នុងករណីដែលមានបញ្ហាទាក់ទងទៅនឹង

៣. វាជាការមួយដែលមិនអាចប្រកែកបានដែលថា អង្គជំនុំជម្រះវិសាមញ្ញមាននីតិសម្បទាគ្រប់គ្រាន់ក្នុងការអនុម័តនូវវិធានផ្ទៃក្នុងរបស់ខ្លួនដើម្បីឱ្យនីតិវិធីស្របទៅតាមបទដ្ឋានអន្តរជាតិ ហើយអង្គជំនុំជម្រះវិសាមញ្ញក៏បានបង្កើតផងដែរនូវយន្តការចាំបាច់នានាពាក់ព័ន្ធទៅនឹងការចោទប្រកាន់ព្រមទាំងការជំនុំជម្រះទៅលើបទឧក្រិដ្ឋក្នុងទ្រង់ទ្រាយធំ ដែលចូលក្នុងសមត្ថកិច្ចតុលាការរបស់ខ្លួន។ ក្នុងករណីនេះ អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើការថ្លឹងថ្លែង ធ្វើយ៉ាងណាឱ្យមានតុល្យភាពរវាងគោលការណ៍ដាច់ខាតនៃការកាត់សេចក្តីដោយសមធម៌ ដោយគោរពសិទ្ធិរបស់មេធាវីការពារប្រព្រឹត្តិទៅក្នុងថេរៈវេលាសមស្រប ជាមួយនឹងសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមនៅក្នុងរឿងក្តីនោះ និងជាពិសេសត្រូវរួមចំណែកក្នុងការប្រឆាំងទៅនឹងនិទ្ទណ្ឌភាពនៃជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត[7]។ គេសង្កេតឃើញផងដែរថា ផលវិបាកមួយក្នុងចំណោមផលវិបាកចម្បងឯទៀតពាក់ព័ន្ធជាមួយនឹងប្រព័ន្ធនៃដើមបណ្តឹងរដ្ឋប្បវេណីដែលចែងដោយច្បាប់កម្ពុជានោះ គឺនៅត្រង់ថាប្រព័ន្ធនេះមិនត្រូវបានបង្កើតឡើងតាំងពីដំបូងមកក្នុងរូបភាពនៃការជំនុំជម្រះក្តីទាក់ទងទៅនឹងឧក្រិដ្ឋដែលប្រព្រឹត្តក្នុងទ្រង់ទ្រាយធំទេដែលប្រការនេះបានបង្កើតឱ្យមានផលវិបាកជាច្រើនដែលមិនអាចប្រកែកបាន ដូចជា:

- ថិរៈវេលានៃអាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញមានកំណត់ ហើយថិរៈវេលានេះពិតជាមិនបង្កភាពងាយស្រួលក្នុងការសម្រេចទៅលើបណ្តឹងដ៏ច្រើនលើសលប់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលសុំឱ្យមានសំណងជាលក្ខណៈបុគ្គលនោះទេ។
- អង្គជំនុំជម្រះវិសាមញ្ញ ពុំមានមូលនិធិក្នុងការជួសជុលសំណងរដ្ឋប្បវេណីដល់ជនរងគ្រោះទេ ហើយម្យ៉ាងទៀត វាជាការឥតប្រយោជន៍ក្នុងការសម្រេចឱ្យមានការជួស

---

ភាពសមស្របគ្នារវាងបទបញ្ញត្តិរបស់កម្ពុជាជាមួយនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ"។

[7] សូមពិនិត្យមើលជាពិសេសសេចក្តីសម្រេចលេខ ៦០/១៤៧ អនុម័តថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០០៥ ដោយអង្គមហាសន្និបាតអង្គការសហប្រជាជាតិ ដែលមានចំណងជើងថា: គោលការណ៍គ្រឹះជាមូលដ្ឋាន និងសេចក្តីណែនាំទាក់ទងដល់សិទ្ធិក្នុងការប្តឹង និងក្នុងការជួសជុលការខូចខាតដល់ជនរងគ្រោះដែលបណ្តាលមកពីការរំលោភជាក់ស្តែងលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។ ឯកសារអង្គការសហប្រជាជាតិលេខA/RES/60/147។

00387105

E72/3



ផុលសំណងជាសាច់ប្រាក់ដែលសរុបមានចំនួនច្រើនប្រឆាំងទៅនឹងបុគ្គលសាមញ្ញម្នាក់ដែលការអនុវត្តនូវសេចក្តីសម្រេចនឹងមានការលំបាកប្រសិនបើបុគ្គលនោះជាអសាធនីយជន។

- ភស្តុតាងដែលបញ្ជាក់ពីវត្តមាននៃការប្រព្រឹត្តិបទឧក្រិដ្ឋក្នុងទ្រង់ទ្រាយធំ មានលក្ខណៈខុសគ្នាពីភស្តុតាងដែលបញ្ជាក់ពីវត្តមាននៃការប្រព្រឹត្តិបទឧក្រិដ្ឋរាប់ពាន់ចំពោះករណីនីមួយៗដោយឡែកពីគ្នា ជាពិសេសក្នុងបរិបទមួយ ដែលអង្គហេតុដែលបានកើតឡើងក្នុងអតីតកាល ជាមួយការបាត់ខ្លួន និងភាពច្របូកច្របូកនៃរបបគ្រប់គ្រងរដ្ឋនោះ។ ជាក់ស្តែង វាមានភាពខុសគ្នារវាងការបង្ហាញថាភូមិមួយត្រូវបានវាយបំបែក និងការបង្ហាញថាដុំថ្មណាមួយបានមកពីភ្នំដែលត្រូវបានគេកម្ទេចបាត់រូបរាងទៅហើយនោះ។
- ការជំនុំជម្រះនៅក្នុងថិរៈវេលាមួយសមស្របមិនអាចធ្វើទៅរួចទេ ប្រសិនណាមានអន្តរាគមន៍ពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណីដ៏ច្រើន ដែលពួកគាត់បានដាក់ពាក្យបណ្តឹងជាលក្ខណៈបុគ្គលហើយដែលគ្មានមេធាវីការពារនោះ។ ម្យ៉ាងទៀត ជនរងគ្រោះអាចនឹងទទួលបានមេធាវីដើម្បីតំណាងឱ្យខ្លួនបាន លុះត្រាតែជនរងគ្រោះនោះប្រមូលផ្តុំគ្នាជាសមូហភាព។
- សិទ្ធិដែលទទួលស្គាល់ចំពោះដើមបណ្តឹងរដ្ឋប្បវេណីនេះមានលក្ខណៈសំខាន់ណាស់ ហើយគេត្រូវធានាថា អ្នកដែលចង់អនុវត្តនូវសិទ្ធិនេះក្នុងអំឡុងនៃការជំនុំជម្រះ ត្រូវតែមានលក្ខណៈសម្បត្តិដែលអាចអនុវត្តសិទ្ធិនេះបាន ដូច្នេះ ត្រូវមានយន្តការត្រួតពិនិត្យមើលអំពីភាពដែលអាចទទួលបាននៃពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលអាចមានចំនួនដ៏ច្រើនលើសលុបនោះ។

៤. ក្នុងហេតុផលដ៏ទូលំទូលាយទាំងនេះ អង្គជំនុំជម្រះវិសាមញ្ញបានចែងក្នុងវិធានផ្ទៃក្នុងរបស់ខ្លួននូវវិធានដែលដកស្រង់ចេញពីច្បាប់របស់កម្ពុជា។ វាមានលក្ខណៈចាំបាច់ និងអាចកើតមានផងដែរនូវការចែងបទបញ្ញតិងទៃផ្សេងទៀត ប៉ុន្តែយើងត្រូវចោទសួរដែរថាតើផលលំបាកទាំងនេះអាចមានហេតុផលសមស្របសម្រាប់បញ្ជាក់នូវការផ្លាស់ប្តូរទាំងស្រុង ពោលគឺការបដិសេធ

តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ? តើគេអាចធ្វើការរិតត្បិតសិទ្ធិទាំងនេះដល់កម្រិតណា ដោយមិនអោយផ្ទុយនឹងច្បាប់ ដោយមិនអោយផ្ទុយពីអត្ថន័យជាមូលដ្ឋាននៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ និងគោលដៅនៃរឿងក្តីទាំងមូលដែលចង់ឱ្យមានការតាំងបណ្តឹងពីរក្នុងពេលតែមួយ គឺបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី ដែលបណ្តឹងទាំងពីរនេះមានទំនាក់ទំនងជាច្រើនរវាងគ្នាទៅវិញទៅមកនោះ។

៥. នៅក្នុងច្បាប់របស់កម្ពុជា បណ្តឹងអាជ្ញាសំដៅទៅលើបណ្តឹងទាំងឡាយដែលធ្វើឡើងដោយព្រះរាជអាជ្ញាក្នុងនាមសង្គមទាំងមូល ហើយបណ្តឹងនេះមានកម្មវត្ថុជាការស្នើឱ្យមានការអនុវត្តច្បាប់ព្រហ្មទណ្ឌទៅលើជនដែលបានប្រព្រឹត្តបទល្មើស ហើយនឹងស្នើសុំឱ្យមានការជួសជុលការខូចខាតនានាដែលបង្កឡើងទៅលើសង្គម។ បណ្តឹងរដ្ឋប្បវេណីមានកម្មវត្ថុធ្វើឱ្យបានការជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើសដល់ភាគីជនរងគ្រោះដោយផ្ទាល់ ដែលគាត់បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[8]។

៦. សម្រាប់ច្បាប់នៃប្រទេសទាំងឡាយណាដែលទទួលស្គាល់ការចូលរួមរបស់ជនរងគ្រោះ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺជាទម្រង់មួយដែលមានលក្ខណៈជឿនលឿនបំផុតស្តីពីការចូលរួមរបស់ជនរងគ្រោះនៅក្នុងនីតិវិធីនៃរឿងក្តីព្រហ្មទណ្ឌ។ ជាក់ស្តែង ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចអនុញ្ញាតិឱ្យជនទាំងឡាយណាដែលអះអាងថាខ្លួនជាជនរងគ្រោះនៃអំពើទាំងឡាយដែលត្រូវបានចាត់ទុកថាជាបទល្មើសអាចចូលខ្លួនមកជាភាគីក្នុងរឿងក្តីមួយ ដែលរឿងក្តីនោះមានគោលដៅលាតត្រដាងការពិតនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ ក៏ដូចជាបទឧក្រិដ្ឋដែលត្រូវបានសន្មត់ថាជាប្រភពបង្កឱ្យមានព្យសនកម្មដល់ជនរងគ្រោះនោះ ហើយនឹងមានគោលដៅស្វែងរក និងផ្តន្ទាទោសទៅលើជនល្មើសនៃបទឧក្រិដ្ឋនោះ។ ជាធម្មតា នៅក្នុងដំណើរការនីតិវិធីនៃរឿងក្តី ភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងសុំនៅក្នុងក្របខណ្ឌនៃបណ្តឹងរដ្ឋប្បវេណី

[8] សូមពិនិត្យមើលមាត្រា ២ និងមាត្រា ៤ នៃក្រមឆ្នាំ២០០៧។

របស់ខ្លួនឱ្យមានការជួសជុលការខូចខាតនានាដែលខ្លួនបានទទួលរងពីបទល្មើសមួយទៅកាន់ចៅក្រមដែលទទួលបន្ទុកលើសំណុំរឿងព្រហ្មទណ្ឌនោះបាន លុះត្រាតែបណ្ដឹងអាជ្ញាដែលបានប្ដឹងចោទប្រកាន់នោះត្រូវបានជំនុំជម្រះដោយចៅក្រមដដែលនោះ ហើយជនជាប់ចោទត្រូវបានរកឃើញថាជាពិរុទ្ធជនពិតប្រាកដមែន។ ដូច្នេះ មិនមែនមានតែនៅដំណាក់កាលនៃការពិនិត្យលើភាពដែលអាចទទួលយកបាន និងមានហេតុផលនៃការដាក់ពាក្យបណ្ដឹងរដ្ឋប្បវេណីទេ ដែលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតិឱ្យចូលរួមនោះ ប៉ុន្តែដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានអនុញ្ញាតិឱ្យមានសកម្មភាពនៅក្នុងរឿងក្ដីបាននៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធី ដែលនីតិវិធីនោះមានកម្មវត្ថុរួម គឺការស្វែងរកការពិតនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទដែលការទទួលខុសត្រូវព្រហ្មទណ្ឌនេះបង្កើតឱ្យមានការទទួលខុសត្រូវរដ្ឋប្បវេណីបន្តទៀត។

៧. ជាក់ស្ដែង ទោះបីជាកម្មវត្ថុនៃបណ្ដឹងអាជ្ញានិងកម្មវត្ថុនៃបណ្ដឹងរដ្ឋប្បវេណីមានលក្ខណៈខុសគ្នាក៏ដោយ ផ្ទុយទៅវិញនៅក្នុងនីតិវិធី បណ្ដឹងទាំងពីរនេះមានទំនាក់ទំនងរវាងគ្នាជាច្រើនដែលធ្វើឱ្យបណ្ដឹងទាំងពីរផ្សាភ្ជាប់គ្នាពីព្រោះថាដើមបណ្ដឹងរដ្ឋប្បវេណីគឺជាភាគីនៃបណ្ដឹងអាជ្ញាផង និងជាភាគីនៃបណ្ដឹងរដ្ឋប្បវេណីផង។ ដើមបណ្ដឹងរដ្ឋប្បវេណីយកចិត្តទុកដាក់ចំពោះការសម្រេចពីបណ្ដឹងអាជ្ញា ដោយសារគាត់មានផលប្រយោជន៍នៅពេលដែលមានការទទួលស្គាល់ពិរុទ្ធភាពរបស់ជនជាប់ចោទនោះ ពោលគឺនៅពេលដែលមានការសម្រេចថាអង្គហេតុដែលទទួលរងការចោទប្រកាន់គឺជាប្រភពដែលបង្កឱ្យមានព្យសនកម្មទៅលើរូបគាត់ដែរនោះ។ ដើមបណ្ដឹងរដ្ឋប្បវេណីទទួលបាននូវសិទ្ធិដែលកំណត់ដោយច្បាប់ ហើយតាមរយៈសិទ្ធិនោះគាត់មានលទ្ធភាពអាចតាំងខ្លួនដោយផ្ទាល់ជាភាគីនៅក្នុងបណ្ដឹងអាជ្ញា។ ជាក់ស្ដែង ភាគីដើមបណ្ដឹងរដ្ឋប្បវេណីអាចជាដើមបណ្ដឹងអាជ្ញាតាមរយៈពាក្យបណ្ដឹង និងការប្ដឹងផ្ទាល់របស់គាត់។ តាមរយៈសំណើសុំបំពេញកិច្ចនៅក្នុងដំណាក់កាលស៊ើបសួរ ដើមបណ្ដឹងរដ្ឋប្បវេណីអាចជួយតម្រែតម្រង់ដល់កិច្ចស៊ើបសួររបស់តុលាការ ហើយក្នុងករណីខ្លះ ដើមបណ្ដឹងរដ្ឋប្បវេណីអាចតម្រែតម្រង់ទិសដៅថ្មីសម្រាប់ការចោទប្រកាន់របស់តុលាការថែមទៀតផង។ តាមរយៈវត្តមាននៅក្នុងអង្គសវនាការដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមទៅក្នុងកិច្ចពិភាក្សាដេញដោលលើការទទួលខុសត្រូវព្រហ្មទណ្ឌ

របស់ជនជាប់ចោទ ដែលនៅពេលនោះ ដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសធ្វើការដេញដោលដោយចំពោះមុខនូវរាល់ភស្តុតាងទាំងឡាយដែលបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចបង្ហាញនូវភស្តុតាងបន្ថែម និងជួយបំភ្លឺដល់កិច្ចពិភាក្សាដេញដោលរបស់តុលាការជាពិសេសបង្ហាញឲ្យកាន់តែច្បាស់នូវការខូចខាតដែលបង្កឡើងដោយអំពើល្មើសនោះ។

៨. អង្គជំនុំជម្រះបានទទួលនូវពាក្យបណ្តឹងរួមគ្នារបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ និងក្រុម២ ដែលបានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការសម្រេចថា តើមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការធ្វើកំណត់សម្គាល់របស់ខ្លួនស្តីពីការកំណត់ទោសដែរឬទេ[9]។ លើសពីនេះ អង្គជំនុំជម្រះបានចោទឡើងនូវសំណួរដែលថា តើភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតិឲ្យចោទជាសំណួរដែលទាក់ទងទៅនឹងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទដែរឬទេ។ ជាការឆ្លើយតប អង្គជំនុំជម្រះបានចេញនូវសេចក្តីសម្រេចផ្ទាល់មាត់ចំនួនពីរ[10] ហើយទាក់ទងទៅដល់សេចក្តីសម្រេចទាំងពីរនោះ ខ្ញុំសូមបញ្ចេញនូវទស្សនៈផ្ទាល់ខ្លួនរបស់ខ្ញុំ ដែលមានលក្ខណៈផ្ទុយគ្នាមួយចំនួន ឬទាំងស្រុងទៅនឹងសេចក្តីសម្រេចនោះ ពីព្រោះខ្ញុំគិតថាសេចក្តីសម្រេចនោះមានលក្ខណៈផ្ទុយទៅនឹងច្បាប់ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះ ពីព្រោះដោយសារខ្ញុំគិតថាសេចក្តីសម្រេចនោះបានកែប្រែដោយគ្មានអំណះអំណាងស្របច្បាប់ នូវតួនាទីនិងអត្ថន័យនៃការចូលខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចុងក្រោយ លើសពីភាពមិនស៊ីសង្វាក់គ្នាមួយចំនួនសេចក្តីសម្រេចនោះថែមទាំងបានបង្កើតឲ្យមានភាពស្រពិចស្រពិលផ្នែកផ្លូវច្បាប់ ដែលអាចបង្កជាព្យសនកម្មទៀតផង។

---

[9] "សំណើសុំរួមគ្នារបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ និង ក្រុម២ ទៅអង្គជំនុំជម្រះដើម្បីស្នើសុំឲ្យមានការចេញ សេចក្តីសម្រេចលើសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីទោស" ថ្ងៃទី៩ ខែ មិថុនា ឆ្នាំ២០០៩ (ឯកសារ E72)។

[10] ប្រតិចារិកនៃសវនាការថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌទី៤៥ ដល់ ៤៧ និងទំព័រទី ៧៩។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C E T C

## I. គោលការណ៍គ្រឹះ និងលក្ខន្តិកៈនៃដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ

៩. វិធាន ២១-១ នៃវិធានផ្ទៃក្នុង បានចែងអំពីគោលការណ៍ដែលថា អង្គជំនុំជម្រះមានលក្ខណៈពិសេស និងមានចំណុចមួយចំនួនដែលត្រូវតែគូសបញ្ជាក់ឱ្យបានច្បាស់៖

"ក. ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ (...)

គ. អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី"។

១០. ម្យ៉ាងទៀត វិធានដដែលនេះបានចែងថា រាល់ឧបករណ៍គតិយុត្តិទាំងឡាយដែលប្រើប្រាស់ដោយអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព..."។

១១. ទោះបីជារាល់ជនរងគ្រោះមិនមែនសុទ្ធតែដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ហើយទោះបីជានៅក្នុងអំឡុងពេលនៃការពិភាក្សាដេញដោល មានដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនត្រូវបានរកឃើញថាពុំមែនជាជនរងគ្រោះដោយផ្ទាល់នៃអំពើដែលបានចោទប្រកាន់ក៏ដោយ ក៏គ្មានអ្វីដែលធ្វើឱ្យគេមិនអាចនិយាយបានថា ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺជាមធ្យោបាយតាមផ្លូវច្បាប់តែមួយគត់របស់ជនរងគ្រោះក្នុងការចូលរួមទៅក្នុងដំណើរការនីតិវិធីនៃរឿងក្តីដែរ។ ដើម្បីធានាឱ្យមានការគោរពដល់សិទ្ធិជនរងគ្រោះ អង្គជំនុំជម្រះត្រូវធានាថា ដើមបណ្តឹងរដ្ឋប្បវេណីអាចអនុវត្តនូវសិទ្ធិរបស់ខ្លួនបានដោយមានប្រសិទ្ធិភាព ដែលសិទ្ធិនោះត្រូវផ្តល់ឱ្យដោយលក្ខន្តិកៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ និងត្រូវធានាថាការជំនុំជម្រះត្រូវប្រព្រឹត្តទៅដោយសមធម៌ ត្រូវគោរពគោលការណ៍ចំពោះមុខ ចំពោះគ្រប់ភាគីទាំងអស់ដោយគ្មានបែងចែក។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C E T C

១២. វិធាន ២៣ នៃវិធានផ្ទៃក្នុង ក្នុងកថាខណ្ឌទី១ និងទី៦ បានចែងថាយ៉ាងច្បាស់ថា នៅពេលដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះក្លាយទៅជាភាគីក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ហើយដើមបណ្តឹងរដ្ឋប្បវេណីដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បី:

"ក. ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម នៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ និង

ខ. អនុញ្ញាតិឲ្យជនរងគ្រោះអាចស្វែងរកសំណងផ្លូវចិត្ត និងសម្ភារភាព[...]"។

១៣. ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីនៃរឿងក្តី។ នៅក្នុងដំណាក់កាលនីមួយៗនៃនីតិវិធី វិធានផ្ទៃក្នុងបានកំណត់អំពីសិទ្ធិរបស់គូភាគី។ ពេលខ្លះសិទ្ធិនេះត្រូវបានប្រគល់ជូនចំពោះតែដើមបណ្តឹងរដ្ឋប្បវេណី និងពេលខ្លះទៀតវាត្រូវបានប្រគល់ចំពោះ "ភាគី"ទាំងអស់ដោយមិនធ្វើការបែងចែក នៅក្នុងករណីបែបនេះ បទបញ្ញតិនេះត្រូវបានចាត់ទុកថាត្រូវអនុវត្តផងដែរទៅលើភាគីដើមបណ្តឹងរដ្ឋប្បវេណី[11]។ ដូច្នេះ លើកលែងតែវិធានផ្ទៃក្នុងមិនបានចែងអំពីការចូលខ្លួនរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬបានរឹតត្បិតសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងច្បាស់នោះ ភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវចាត់ទុកថាទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចដូចគ្នាទៅនឹងភាគីដទៃទៀតនៃរឿងក្តី។ ការបកស្រាយផ្សេងពីនេះ គឺជាការបកស្រាយផ្ទុយទៅនឹងច្បាប់។

១៤. ទាក់ទងដល់ការរឹតត្បិតជាក់ច្បាស់នូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដោយវិធានផ្ទៃក្នុង យើងអាចលើកជាឧទាហរណ៍ វិធាន ៨៩ ស្ទួន វិធាននេះបានទុកលទ្ធភាពតែចំពោះសហព្រះរាជអាជ្ញា និងជនជាប់ចោទ ឬមេធាវីរបស់ខ្លួនប៉ុណ្ណោះ ក្នុងការធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបអំពី

[11] សូមពិនិត្យមើលនិយមន័យនៃពាក្យ "ភាគី" នៅក្នុងសទ្ទានុក្រមដែលភ្ជាប់ជាមួយវិធានផ្ទៃក្នុង។ ភាគី "សម្តៅទៅលើសហព្រះរាជអាជ្ញា ជនត្រូវចោទ ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • E T C

ការចោទប្រកាន់ចំពោះជនជាប់ចោទនៅក្នុងអំឡុងសវនាការលើអង្គសេចក្តី។ ជាមួយគ្នានេះដែរ វិធាន ៨២-៣ នៃវិធានផ្ទៃក្នុងពុំបានចែងអំពីការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងកិច្ចពិភាក្សាដេញដោលរបស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចអំពីសំណើសុំឱ្យមានការដោះលែងជនជាប់ចោទនោះទេ។ កិច្ចពិភាក្សានេះត្រូវបានអនុញ្ញាតិតែចំពោះមេធាវីការពារក្តី និងសហព្រះរាជអាជ្ញាប៉ុណ្ណោះ។

១៥. មានការរឹតត្បិតសិទ្ធិជាក់ច្បាស់ផ្សេងទៀត ដែលទាក់ទងដល់លទ្ធភាពក្នុងការធ្វើបណ្តឹងឧទ្ធរណ៍

- ករណីទី១ ទាក់ទងដល់ដីការបស់សហចៅក្រមស៊ើបអង្កេត វិធាន ៧៤-៣ [12] បានកម្រិតប្រភេទនៃដីកាដែលដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំង ហើយក្នុងករណីដែលមានសេចក្តីសម្រេចតម្កល់រឿងទុកមិនចាត់ការ ដើមបណ្តឹងរដ្ឋប្បវេណីនឹងអាចធ្វើបណ្តឹងឧទ្ធរណ៍បាន តែក្នុងករណីដែលបណ្តឹងឧទ្ធរណ៍នោះត្រូវបានធ្វើរួមគ្នាជាមួយនឹងសហព្រះរាជអាជ្ញា[13]។
- ករណីទី២ វិធាន ១០៥-១ គ និង ឃ[14] បានអនុញ្ញាតិឱ្យដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹងសារទុក្ខទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះផលប្រយោជន៍រដ្ឋប្បវេណីបានតែក្នុងករណីដែលមានបណ្តឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាក្នុងរឿងនោះតែប៉ុណ្ណោះ។[15]

[12] សូមពិនិត្យមើលមាត្រា ២៦៨ នៃក្រមឆ្នាំ ២០០៧។

[13] ក្នុងគ្រប់កាលៈទេសៈទាំងអស់ សេចក្តីសម្រេចដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ មិនអាចត្រូវបានប្តឹងឧទ្ធរណ៍ដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីទេ។

[14] សូមពិនិត្យមើលមាត្រា ៣៧៥ នៃក្រមឆ្នាំ ២០០៧។

[15] ដើមបណ្តឹងរដ្ឋប្បវេណីគ្មានលទ្ធភាពក្នុងការប្តឹងជំទាស់ដោយខ្លួនផ្ទាល់ទៅនឹងសេចក្តីសម្រេចដោះលែង ឬគ្មានលទ្ធភាពក្នុងការស្នើសុំឱ្យមានការកែប្រែទម្រង់នៃទោសដែលត្រូវផ្តន្ទាទៅលើជនជាប់ចោទទេនោះ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C • C E T C

១៦. លើសពីនេះទៅទៀត វិធានផ្ទៃក្នុងបានប្រគល់យ៉ាងច្បាស់ ជូនដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ជូនដល់"ភាគី"ទាំងឡាយ ដែលមានន័យថាដើមបណ្តឹងរដ្ឋប្បវេណីក៏ទទួលនូវសិទ្ធិចាំបាច់ទាំងនេះដែរនោះ គឺសិទ្ធិដូចខាងក្រោម:

- នៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ[16] ដើមបណ្តឹងរដ្ឋប្បវេណីទទួលបានដោយផ្ទាល់ ឬតាមរយៈមេធាវីរបស់ខ្លួន នូវសិទ្ធិដូចគ្នាទៅនឹងគូរភាគីដទៃទៀត មិនថាសិទ្ធិក្នុងការតាំងសំណួរនៅក្នុងដំណាក់កាលតទល់គ្នាដោយផ្ទាល់រវាងជនត្រូវចោទ និងភាគីឬសាក្សីដទៃទៀត (វិធាន ៥៨-៤) ឬសិទ្ធិក្នុងការស្នើសុំឱ្យមានកិច្ចស៊ើបសួរទេ (វិធាន ៥៩)[17] ឬម្យ៉ាងទៀត ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាបដិសេធពុំសម្រេចតាមសំណើសុំណាមួយ ដោយគិតទាំងសំណើសុំរបាយការណ៍របស់អ្នកជំនាញ ឬសំណើសុំរបាយការណ៍របស់អ្នកជំនាញដាក់បន្ទុក (វិធាន ៧៥-៤)[18]។

ក្នុងដំណាក់កាលនេះ ការសិក្សាពីបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ គឺជាភារកិច្ចទាំងស្រុងរបស់សហចៅក្រមស៊ើបអង្កេត[19] ដោយហេតុថាការសិក្សានេះអាចជាមូលដ្ឋាននៃការដាក់បន្ទុក ឬដោះបន្ទុកទៅលើជនត្រូវចោទ[20]។ វិធានផ្ទៃក្នុងមិនបានធ្វើការបែងចែកណាមួយរវាងសំណើសុំ របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធជាមួយនឹងភស្តុតាងនៃអង្គហេតុដែលជា

---

[16] គួររំលឹកផងដែរថា ឈរលើមូលដ្ឋាននៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរ កិច្ចស៊ើបសួររបស់តុលាការមានកម្មវត្ថុជាការបំពេញនូវកិច្ចចាំបាច់នានាដើម្បី "លាតត្រដាងនូវការពិត" និងដើម្បីអនុញ្ញាតិឱ្យសហចៅក្រមស៊ើបអង្កេតអាចទទួលបាននូវភស្តុតាងនានាដើម្បីដាក់បន្ទុក ឬដោះបន្ទុកទៅលើជនត្រូវចោទ។

[17] មាត្រា ១៣៤ នៃក្រមឆ្នាំ ២០០៧ មានចែងនូវបទបញ្ញត្តិស្រដៀងគ្នាទៅនឹងវិធាន ៥៨-៤ និង ៥៩ នៃវិធានផ្ទៃក្នុង។

[18] សូមពិនិត្យមើលមាត្រា ២៦៨ នៃក្រមឆ្នាំ ២០០៧។

[19] គួរកត់សម្គាល់ថា ក្រមឆ្នាំ ២០០៧ បានចែងយ៉ាងច្បាស់អំពីលទ្ធភាពក្នុងការសុំឱ្យមានរបាយការណ៍របស់អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ និងចិត្តសាស្ត្រទៅលើជនត្រូវចោទ (មាត្រា ១៦៧ កថាខណ្ឌទី៣) ក៏ដូចជាសុំឱ្យមានការជូនដំណឹងអំពីរបាយការណ៍នោះទៅដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងលទ្ធភាពក្នុងការសុំឱ្យមានរបាយការណ៍ប្រតិកោសលវិច័យផងដែរ (មាត្រា ១៧០ កថាខណ្ឌទី៤ និង៥)។

[20] ច្បាប់បារាំងប្រើពាក្យថា "ធាតុផ្សំដើម្បីដាក់បន្ទុក និងធាតុផ្សំដើម្បីដោះបន្ទុក"។ ធាតុផ្សំទាំងនេះមិនមែនកំរិតត្រឹមតែធាតុផ្សំដែលជាប់ទាក់ទងនឹងពិរុទ្ធភាព ឬគ្មានពិរុទ្ធរបស់ជនត្រូវចោទប៉ុណ្ណោះទេ ប៉ុន្តែវាជាប់ទាក់ទងផងដែរទៅនឹងការបន្ថែម ឬបន្ថយទម្ងន់នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាយថាហេតុរបស់ជនជាប់ចោទ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C E T C

00387113



កម្មវត្ថុនៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរ និងសំណើសុំឱ្យមានការសិក្សាទៅលើបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទនោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិស្នើសុំឱ្យមានការស្តាប់យកចម្លើយរាល់សាក្សីសំខាន់ៗក្នុងរឿងក្តី និងអាចស្នើសុំឱ្យមានរបាយការណ៍របស់អ្នកជំនាញ ឬរបាយការណ៍របស់អ្នកជំនាញប្រតិកោសលវិច័យទាក់ទងដល់ការវិភាគផ្នែកវិកលចរិត ឬការវិភាគផ្នែកចិត្តសាស្ត្រផងដែរ។ លើសពីនេះទៅទៀត ដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់នូវព័ត៌មានសំខាន់ៗ ហើយជាពិសេសទៅទៀត អាចបំភ្លឺដល់តុលាការអំពីបុគ្គលិកលក្ខណៈអត្តចរិតរបស់ជនជាប់ចោទ ដោយពិនិត្យមើលអាកប្បកិរិយារបស់ជនជាប់ចោទ នៅពេលមុន និងក្រោយអង្គហេតុដែលបានលើកឡើងក្នុងបទចោទប្រកាន់។

- នៅក្នុងអំឡុងពេលសវនាការចេញសេចក្តីសម្រេច ដើមបណ្តឹងរដ្ឋប្បវេណីនូវទទួលបាននូវសិទ្ធិនានា ដូចភាគីដទៃទៀតនៃរឿងក្តីដែរ[21]។ ជាក់ស្តែង ដើមបណ្តឹងរដ្ឋប្បវេណីអាចបង្ហាញនៅក្នុងអង្គសវនាការបឋម នូវបញ្ជីសាក្សី (វិធាន ៨០)[22] ក៏ដូចជាបញ្ជីឯកសារថ្មី (វិធាន ៧៩-៩ឃ) ឬ ស្នើសុំទៅអង្គជំនុំជម្រះឱ្យមានការកោះហៅសាក្សីថ្មីនៅក្នុងដំណាក់កាលនៃរឿងក្តី (វិធាន ៨៧-៤)។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិពិនិត្យសំណុំរឿងតាមរយៈមេធាវីរបស់ខ្លួន (វិធាន ៨៦)។ លើសពីនេះទៅទៀត ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិដាក់សេចក្តីសន្និដ្ឋានទាក់ទងដល់ភស្តុតាងរហូតដល់បិទកិច្ចពិភាក្សាដេញដោល[23]។ ខ្លួនមានសិទ្ធិឱ្យគេស្តាប់យកចម្លើយ (វិធាន ៩១) [24] និងមានសិទ្ធិតាំងសំណួរទៅគ្រប់ភាគីទាំងអស់ដែលមានវត្តមាននៅក្នុងអង្គសវនាការ ដូចជាជនជាប់ចោទ សាក្សី ឬអ្នកជំនាញជាដើម (វិធាន ៩០-២, វិធាន

---

[21] ប្រតិចារិកនៃសវនាការថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០០៩។ សហព្រះរាជអាជ្ញាអន្តរជាតិ លោក Vincent de Wilde d'Estmael បានរំលឹកឡើងថា "នៅក្នុងប្រព័ន្ធច្បាប់របស់កម្ពុជា គ្មានវិធានណាមួយដែលកំណត់នូវការបែងចែកដោយចាត់ទុកដើមបណ្តឹងរដ្ឋប្បវេណីជាភាគីដែលគ្មានសារៈប្រយោជន៍ ជាភាគីដែលស្នាក់ស្មើនៃរឿងក្តីនោះទេ" ទំព័រ ៥០។ ទំព័រ ៤៥ ក្នុងភាសាអង់គ្លេស។

[22] សូមពិនិត្យមើលមាត្រា ២៩៨ នៃក្រមឆ្នាំ ២០០៧។

[23] សូមពិនិត្យមើលមាត្រា ៣៣៤ នៃក្រមឆ្នាំ ២០០៧។

[24] សូមពិនិត្យមើលមាត្រា ៣២៦ នៃក្រមឆ្នាំ ២០០៧។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

៩១)[25]។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីក៏មានសិទ្ធិដាក់នូវសេចក្តីសន្និដ្ឋាន (វិធាន ៩២) ព្រមទាំងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល និងសេចក្តីសន្និដ្ឋានឆ្លើយតបវិញបាន (វិធាន ៩៤)[26]។ គ្មានពេលណាមួយ ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានរឹតត្បិតសិទ្ធិ លើសពីអ្វីដូចបានបញ្ជាក់ពីខាងដើម ជាពិសេសវិធានផ្ទៃក្នុងមិនបានចែងអំពីការរឹតត្បិតណាមួយដោយសារតែការបង្ហាញ ឬការពិភាក្សាដេញដោលលើភស្តុតាងមនជាប់ពាក់ព័ន្ធជាមួយនឹងករណីមួយចំនួននោះ។

១៧. ជាងនេះទៀត ការអនុវត្តសិទ្ធិទាំងនេះក៏ត្រូវផ្សារភ្ជាប់ទៅនឹងសិទ្ធិមួយដែលមានលក្ខណៈជាសារវ័ន្ត ពោលគឺផ្សារភ្ជាប់ទៅនឹងគោលការណ៍ចំពោះមុខដែលបានចែងនៅក្នុងវិធាន ២១ ដែលតម្រូវឱ្យចៅក្រម និងភាគីនានាធ្វើការពិភាក្សាលើភស្តុតាងទាំងអស់។ ជាការពិត វិធាន៨៧-២[27] ចែងថា "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល"។ ជាបឋម វិធាននេះសំដៅលើភស្តុតាងទាំងអស់ដែលលើកឡើងនៅក្នុងសវនាការ ដោយពុំមានការបែងចែក ថាភស្តុតាងទាំងនោះទាក់ទងនឹងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទច្រើនជាងអង្គហេតុផ្ទាល់នោះទេ។ លើសពីនេះទៅទៀត វិធានដដែលនេះផ្តោតទៅលើសេចក្តីសម្រេចទាំងឡាយរបស់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះមិនត្រូវបានដាក់កំហិតឱ្យលើកឡើងតែចំពោះសេចក្តីសម្រេចតែមួយគត់ស្តីពីពិរុទ្ធភាពនោះទេ ប៉ុន្តែក៏អាចធ្វើសេចក្តីសម្រេចទាក់ទងនឹងទោសផងដែរ នៅក្នុងករណីចាំបាច់[28]។ គោលការណ៍នៃការពិភាក្សាតទល់គ្នាមិនមែនយកមកអនុវត្តត្រឹមតែការពិភាក្សាលើឯកសារដែលលើកឡើងសម្រាប់ការជជែកដេញដោលប៉ុណ្ណោះទេ ប៉ុន្តែគោលការណ៍នេះជាប់ទាក់ទងផងដែរនឹងធាតុផ្សំនៃភស្តុតាងទាំងអស់ មានជាអាទិ៍សក្ខីកម្ម។ ហើយនេះគឺជាអ្វីមួយដែល

[25] សូមពិនិត្យមើលមាត្រា ៣២៥ នៃក្រមឆ្នាំ ២០០៧។

[26] មាត្រា ៣៣៥ នៃក្រមឆ្នាំ ២០០៧ បានចែងនូវបទបញ្ញត្តិស្រដៀងគ្នាទៅនឹងវិធាន ៩២ និង ៩៤ នៃវិធានផ្ទៃក្នុង។

[27] សូមអានមាត្រា ៣២១ នៃក្រមឆ្នាំ ២០០៧។

[28] សូមរំឭកថា ភាពខុសគ្នារវាងសវនាការដែលនិយាយតែអំពីពិរុទ្ធភាព និង សវនាការទាក់ទងការជជែកពិភាក្សាស្តីពីទោស មិនមាននៅ អង្គជំនុំជម្រះវិសាមញ្ញ ទេ ហើយដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមនៅគ្រប់សវនាការទាំងអស់។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE * E C C C * E T C

អាចឲ្យគេកំណត់បានថា ភាគីនីមួយៗមានសិទ្ធិសាកសួរសាក្សី។ ហេតុដូច្នេះ សេចក្តីសម្រេចបដិសេធមិនឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចោទសួរសាក្សីនិងអ្នកជំនាញមួយចំនួន គឺពិតជាផ្ទុយទៅនឹងគោលការណ៍នៃការពិភាក្សាតទល់ចំពោះមុខទៅលើគ្រប់ធាតុផ្សំនៃភស្តុតាងពីសំណាក់គ្រប់ភាគីនៃរឿងក្តី ដូចមានចែងក្នុងវិធានផ្ទៃក្នុង។

១៨. ម្យ៉ាងទៀត ពុំមានភាគីណាមួយនៅក្នុងសវនាការ ហ៊ានអះអាងថា នៅក្នុងច្បាប់កម្ពុជាមានការហាមឃាត់ជាគោលលការណ៍ទៅលើសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចោទសួរសាក្សី អ្នកជំនាញ ឬជនជាប់ចោទ លើបញ្ហាដែលទាក់ទងនឹងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទនោះទេ ឬសូម្បីតែពិភាក្សាលើសារៈសំខាន់នៃធាតុផ្សំភស្តុតាងក្នុងហេតុផលដែល ថាវាអាចជាប់ទាក់ទងជាមួយនឹងឯបុគ្គលិកលក្ខណៈរបស់ជនល្មើសនោះក៏គ្មានដែរ។ ហើយជាក់ស្តែង ពុំមានបទបញ្ញត្តិណាមួយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក៏ដូចជានៅក្នុងវិធានផ្ទៃក្នុងបាន ចែងអំពីការបែងចែកណាមួយដោយផ្អែកទៅលើកម្មវត្ថុនៃសក្ខីកម្ម អ្នកជំនាញ ឬដោយផ្អែកទៅលើគ្រប់ធាតុផ្សំនៃភស្តុតាងដទៃទៀតដែលបានដាក់ទៅក្នុងកិច្ចពិភាក្សាតទល់គ្នារបស់ភាគីទេ។ ដូច្នេះ តើត្រូវធ្វើដូចម្តេចដើម្បីយល់អំពីហេតុផលនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ នៅពេលដែលសេចក្តីសម្រេចនេះផ្អែកទៅលើការបកស្រាយដែលអាចមានការយល់ឃើញខុសៗគ្នានៅឡើយនូវតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយដែលតាមរយៈការបកស្រាយនេះ អង្គជំនុំជម្រះក៏បានទាញចេញនូវសេចក្តីសន្និដ្ឋាននានារបស់ខ្លួនដែលមិនបានចែងដោយច្បាប់នោះ?

## II. តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី

១៩. តាមរយៈសេចក្តីសម្រេចទីមួយ អង្គជំនុំជម្រះបាន "បង្គាប់មិនឲ្យដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញនូវសេចក្តីកត់សម្គាល់របស់ខ្លួនទាក់ទងនឹងការកំណត់ទោស ដោយហេតុថា៖

- ក) ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចបញ្ចេញយោបល់លើទោសដែលត្រូវកំណត់បានទេ

- ខ) ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចបង្ហាញនូវហេតុផលផ្លូវច្បាប់ ទាក់ទងនឹងការកំណត់ទោសបានទេ ហើយ
- គ) ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចបង្ហាញនូវសេចក្តីកត់សម្គាល់ និងការវាយតម្លៃអំពីកត្តានានាដែលទាក់ទងនឹងសេចក្តីសម្រេចស្តីពីការកំណត់ទោសបានទេ ក្រៅតែពីកត្តាដែលទាក់ទងនឹងពិរុទ្ធភាពឬគ្មានពិរុទ្ធរបស់ជនជាប់ចោទ និងដែលទាក់ទងនឹងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធតែប៉ុណ្ណោះ”[29]។

ខ្ញុំយល់ស្របជាមួយនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទាក់ទងនឹងចំណុច ក) និង ខ) នៃសេចក្តីសម្រេចនោះ ប៉ុន្តែខ្ញុំមានយោបល់ផ្សេងទាក់ទងនឹងចំណុច គ)។

២០. តាមរយៈសេចក្តីសម្រេចទីពីរ អង្គជំនុំជម្រះបានសម្រេចមិនអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីតាំងសំណួរទៅជនជាប់ចោទទាក់ទឹងនឹងបុគ្គលិកលក្ខណៈរបស់ខ្លួន ព្រមទាំងទៅសាក្សី និងអ្នកជំនាញដែលនឹងបង្ហាញខ្លួននៅអង្គសវនាការទាក់ទងនឹងប្រធានបទនេះ[30]ទេ។ ខ្ញុំមិនយល់ស្របជាមួយការហាមឃាត់បែបនេះទ។

២១. ដោយគិតដល់ទំនាក់ទំនងដែលមានរវាងបញ្ហាដែលលើកឡើងក្នុងសេចក្តីសម្រេចផ្ទាល់មាត់ទាំងពីរ ដែលជាកម្មវត្ថុនៃសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរតែមួយនោះ វាគឺជាការល្អដែលគួរតែចេញយោបល់ដោយមានសម្អាងហេតុតែមួយគត់ ទាក់ទងនឹងមតិជំទាស់ផ្សេងគ្នាទាំងនេះ។

២២. ដោយសារតែការបញ្ជាក់របស់ខ្លួនមានភាពមិនច្បាស់លាស់ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុមទី១ និងក្រុមទី២ បានផ្តោតការយកចិត្តទុកដាក់ទៅលើទិដ្ឋភាពតែមួយគត់នៃបញ្ហា

---

[29] សូមអានកថាខណ្ឌទី១ នៃសេចក្តីសម្រេចតាមមតិភាគច្រើនរបស់ចៅក្រមនៃអង្គជំនុំជម្រះ និងប្រតិចារិកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ពីកថាខណ្ឌទី ៤៥ ដល់ ៤៧។

[30] ប្រតិចារិកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ទំព័រ ៧៩។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • E T C

នៃការចូលរួមរបស់ភាគីនៅក្នុងការពិភាក្សាលើភស្តុតាង ហើយបានធ្វើឱ្យគេគិតថា ដើមបណ្តឹងរដ្ឋប្បវេណីបានទាមទារសិទ្ធិចូលរួមនោះ ជាសំខាន់គឺក្នុងគោលបំណងដាក់សម្ពាធលើអង្គជំនុំជម្រះ ទាក់ទងនឹងការកំណត់ទោសសម្រាប់ជនជាប់ចោទ។ ជាការឆ្លើយតប សេចក្តីសម្រេចផ្ទាល់មាត់ទាំងពីរបានចាត់ទុកថា ការពិភាក្សាលើធាតុផ្សំនៃបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ គឺជាការជជែកពិភាក្សាមួយដែលទាក់ទងនឹងកត្តានានាដែលត្រូវយកមកពិចារណា ដើម្បីធ្វើការកំណត់ទោស។ អង្គជំនុំជម្រះបានសន្និដ្ឋានថា ការជជែកពិភាក្សានោះស្ថិតនៅក្រៅពីដែនអន្តរាគមន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដោយហេតុថា តាងនាមឱ្យផលប្រយោជន៍ទូទៅ មានតែសហព្រះរាជអាជ្ញាតែមួយគត់ដែលទទួលបន្ទុកស្នើសុំការដាក់ទណ្ឌកម្ម។ ហើយតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានកំណត់នៅត្រឹមតែការជជែកពិភាក្សាតែមួយគត់ ដែលតាមរយៈការពិភាក្សានេះ ខ្លួនអាចលើកឡើងពីផលប្រយោជន៍ផ្ទាល់ខ្លួន ដូចជាការជជែកពិភាក្សាលើភស្តុតាងនៃពិរុទ្ធភាពរបស់ជនជាប់ចោទនៅចំពោះមុខអង្គហេតុទាក់ទងនឹងឧក្រិដ្ឋកម្មដែលបណ្តាលឱ្យមានព្យសនកម្មមកលើខ្លួន និងអំពីសំណង។

២៣. តាមការជាក់ស្តែង មានផលប្រយោជន៍រួមរវាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា នៅពេលមានការលើកឡើងទាក់ទងនឹងការបង្ហាញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ប៉ុន្តែហួសពីផលប្រយោជន៍នេះ មានភាពខុសគ្នាដ៏ចំបងរវាងពួកគេ ដោយហេតុថា មានតែសហព្រះរាជអាជ្ញាតែមួយគត់ដែលមានសមត្ថកិច្ចដើម្បីស្នើសុំការដាក់ទោស។ ជាការពិត គឺមិនមែនដើមបណ្តឹងរដ្ឋប្បវេណីទេ ដែលត្រូវធ្វើការអត្ថាធិប្បាយណាមួយទាក់ទងនឹងអ្វីដែលខ្លួនអាចយល់ឃើញថា ជាទោសត្រឹមត្រូវ ឬមិនត្រឹមត្រូវ និងទាក់ទងនឹងបញ្ហាគតិយុត្តដែលអាចទាក់ទងនឹងទោស ជាឧទាហរណ៍ ករណីនៃការស្របបទល្មើស ឬករណីបូកបទល្មើសច្រើនបទ[31] (le cas de concours ou de cumul d'infractions)។

---

[31] ការអនុវត្តទោសគឺជាសមត្ថកិច្ចតែមួយគត់របស់រដ្ឋ ហើយការបកស្រាយវិធានច្បាប់នានាដែលទាក់ទងនឹងការអនុវត្តទោសនេះមិនទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីទេ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • C E T C

២៤. ការណ៍ដែលដាក់លាយឡំបញ្ចូលគ្នានូវតួនាទីរបស់អាជ្ញាធរផ្នែកចោទប្រកាន់ ដែលតំណាងឱ្យសមូហភាពដែលមានលក្ខណៈជាតិ ឬអន្តរជាតិក៏ដោយ ជាមួយនឹងតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺជាគ្រោះថ្នាក់មួយ។ ពិតជាត្រឹមត្រូវណាស់ដែលនិយាយថា ក្នុងឋានៈខ្លួនជាអ្នកតំណាងឱ្យរដ្ឋ ឬសហគមអន្តរជាតិ សហព្រះរាជអាជ្ញាគឺជាតួអង្គតែមួយគត់ដែលអាចបញ្ចេញយោបល់ដើម្បីផលប្រយោជន៍យុត្តិធម៌[32] ដែលត្រូវបានចាត់ទុកថាជាផលប្រយោជន៍ទូទៅ។ ត្រូវតែបញ្ជាក់អះអាងដោយច្បាស់លាស់ថា គឺមិនមែនដើមបណ្តឹងរដ្ឋប្បវេណីទេដែលត្រូវក្លាយខ្លួនជាជំនួយការរបស់ស្ថាប័នសាធារណៈដែលមានភារកិច្ចដាក់សម្ពាធ ហើយរឹតតែមិនអាចក្លាយខ្លួនជាព្រះរាជអាជ្ញាពិសេស ដែលទទួលបន្ទុកចោទប្រកាន់ការសងសឹកជាលក្ខណៈឯកជនមួយក៏ទេដែរ។

២៥. ម្យ៉ាងទៀត គួរគូសបញ្ជាក់ថា នៅប្រទេសកម្ពុជា ព្រះរាជអាជ្ញាគឺជាចៅក្រមនៅក្នុងផ្នែកយុត្តាធិការដែលមានបេសកកម្មដាក់ឱ្យអនុវត្តច្បាប់ព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញាមិនមែនជាភាគីមួយដែលត្រូវយល់ក្នុងន័យធម្មតានោះទេ ប៉ុន្តែត្រូវស្ថិតនៅឱ្យហួសពីការជជែកពិភាក្សា "ដែលមានលក្ខណៈជាភាគីសុទ្ធសាធ"។ ហើយប្រសិនបើខ្លួនយល់ឃើញថា លក្ខខណ្ឌនានាដែលចែងដោយច្បាប់មិនត្រូវបានបំពេញទេនោះ គឺជាករណីយកិច្ចរបស់ខ្លួនដែលត្រូវស្នើសុំការដោះលែងជនជាប់ចោទ។ ទោះជាយ៉ាងណាក៏ដោយ សញ្ញាណទាក់ទងនឹងផលប្រយោជន៍យុត្តិធម៌ ឬនីតិវិធីប្រកបដោយសមធម៌ ផាត់ចោលនូវគំនិតសងសឹកដែលនឹងមិនអាចយកមកពិចារណាអំពីការដាក់ទោសឡើយ។

២៦. ដោយបន្ថយលទ្ធភាពបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីមកនៅត្រឹមផ្នែកតែមួយគត់នៃសាលក្រមដែលទាក់ទងនឹងផលប្រយោជន៍រដ្ឋប្បវេណីរបស់ខ្លួន ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលបានអនុម័តនៅឆ្នាំ២០០៧ បានដាក់ដើមបណ្តឹងរដ្ឋប្បវេណីឱ្យស្ថិតនៅក្នុងតួនាទីដ៏ត្រឹមត្រូវរបស់ខ្លួនវិញ។ ប៉ុន្តែ ក្រមឆ្នាំ២០០៧គ្រាន់តែលុបចោលបទបញ្ញត្តិពិសេស និងតែមួយគត់នៅក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជាតែប៉ុណ្ណោះ ដែលតាមបទបញ្ញត្តិនោះ ដើមបណ្តឹងរដ្ឋប្ប

[32] សូមអានមាត្រា ៤ និង ៣៣៨ នៃក្រមឆ្នាំ ២០០៧។

វេណីអាចប្ដឹងឧទ្ធរណ៍ឡើងវិញប្រឆាំងនឹងសេចក្ដីសម្រេច ដើម្បីទទួលបាននូវការសើរើលើទោស មួយដែលខ្លួនយល់ឃើញថាមិនមានលក្ខណៈសមស្រប (ឬមួយក៏មានលក្ខណៈធ្ងន់ធ្ងរពេក ឬមួយក៏ស្រាលពេក)[33]។ ទន្ទឹមនឹងនេះ ត្រូវកំណត់ថាតើអ្វីទៅជាវិសាលភាពនៃការពិភាក្សាលើពិរុទ្ធភាព និងតើអ្វីទៅជាតួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងការជជែកពិភាក្សានេះ?។

២៧. ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមនៅក្នុងការជជែកពិភាក្សា ស្ដីពីទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណីរបស់ជនជាប់ចោទ ទាំងនៅក្នុងពេលបង្ហាញភស្ដុតាងដោយផ្ទាល់ និងទាំងនៅក្នុងពេលពិភាក្សាដេញដោលចុងក្រោយរបស់ពួកគេ។ ប៉ុន្តែ នៅក្នុងការជជែកពិភាក្សាទាំងនោះ ជាញឹកញាប់ គឺមិនអាចបែងចែកដាច់ពីគ្នាទេនូវអ្វីដែលត្រូវយកមកគិតគូរជាចាំបាច់ដើម្បីម្យ៉ាង បង្ហាញអំពីពិរុទ្ធភាព ឬសិទ្ធិទទួលសំណង និងម្យ៉ាងទៀត អំពីអ្វីដែលត្រូវតែកំណត់អំពីទោសសមស្រប។ បញ្ហានេះរឹតតែពិតប្រាកដទៅទៀតចំពោះអ្វីដែលទាក់ទងនឹងអង្គហេតុ ដែលភាពធ្ងន់ធ្ងរនៃអង្គហេតុនេះ គឺជាសមាសភាពមួយដែលត្រូវតែយកមកគិតគូរនៅពេលធ្វើការសម្រេចដាក់ទោស ដោយនៅក្នុងនោះត្រូវគិតទាំងផលវិបាកសម្រាប់ជនរងគ្រោះផងដែរ ។ ម្យ៉ាងទៀត គឺជាការពិតដែលគេមិនអាចវាយតម្លៃពិរុទ្ធភាពរបស់ជនជាប់ចោទតាមរបៀបអរូបី ឬប្រាកចាកពីតថភាពជាក់ស្ដែងបានទេ។ ហើយនៅក្នុងការជជែកពិភាក្សា គេមិនអាចញែកចេញដាច់ពីគ្នាបានទេនូវធាតុផ្សំដែលជាផ្នែកមួយនៃការយល់ដឹងអំពីអង្គហេតុ និងធាតុផ្សំដែលជាផ្នែកមួយនៃការយល់ដឹងអំពីមនុស្សដែលបានបង្កអោយមានអង្គហេតុនោះទេ។ ហើយធាតុផ្សំទាំងនោះអាចជាធាតុដាក់បន្ទុក ឬដោះបន្ទុក។ ជាទូទៅ ធាតុផ្សំទាំងនោះមានរួចទៅហើយនៅក្នុងសំណុំរឿងស៊ើបអង្កេតដែលគ្រប់ភាគីទាំងអស់បានមានលទ្ធភាពចូលរួម។ ធាតុផ្សំទាំងនោះអាចទាក់ទងនឹងការជជែក

---

[33] តាមការពិត មាត្រា ១៦១ នៃច្បាប់ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៣ ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ត្រូវបានបកស្រាយថា បានផ្ដល់ជាអាទិ៍នូវសិទ្ធិដល់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការប្ដឹងសារទុក្ខ ដើម្បីឱ្យគេពិនិត្យទោសឡើងវិញ។ ប៉ុន្តែកំណែទម្រង់ដែលដាក់បញ្ចូលទៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ថ្មី គ្រាន់តែប្រគល់ឱ្យវិញនូវសិទ្ធិប្ដឹងឧទ្ធរណ៍របស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងស្ថានភាពដែលមានពីមុនស្រាប់ ដោយហេតុថា មាត្រា ៥០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៦៤ បានចែងរួចហើយថា "ដើមបណ្ដឹងរដ្ឋប្បវេណីអាចធ្វើការតវ៉ាតែចំពោះសាលក្រមនិងសាលដីកាណាដែលប៉ះពាល់ដល់ផលប្រយោជន៍រដ្ឋប្បវេណីរបស់ខ្លួនតែប៉ុណ្ណោះ [...]"។

00387120

E72/3



ពិភាក្សាស្តីពីសមត្ថភាពនៃគំនិតវែកញែករកខុសត្រូវរបស់ជនជាប់ចោទ ឬស្តីពីអត្ថិភាពនៃស្ថានភាព "សម្ពាធផ្នែកផ្លូវចិត្ត" ដែលអាចមានផលប៉ះពាល់ដោយផ្ទាល់ទៅលើទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ។

២៨. នៅក្នុងរឿងក្តីមួយ ផលប្រយោជន៍នៃយុត្តិធម៌គឺអនុញ្ញាតឲ្យស្វែងយល់មិនត្រឹមតែអំពីអ្វីដែលជាអង្គហេតុដែលត្រូវបានប្រព្រឹត្តដោយពិតប្រាកដប៉ុណ្ណោះទេ ប៉ុន្តែក៏អនុញ្ញាតអោយស្វែងយល់ផងដែរថា តើអង្គហេតុទាំងនោះត្រូវបានប្រព្រឹត្តដោយចេតនាដែរ ឬទេ ហើយមកពីមូលហេតុអ្វី។ ជាការពិត ការជជែកពិភាក្សារបស់តុលាការមិនមែនកម្រិតមកនៅត្រឹមសំណួរតែមួយគត់ដែលថា "តើជនជាប់ចោទបានធ្វើអ្វីខ្លះ?" នោះទេ ប៉ុន្តែក៏ចោទសួរផងដែរថា "ហេតុអ្វីបានជាជនជាប់ចោទបានធ្វើអំពីទាំងនោះ?"។ ដូចនេះ ការចោទសួរសំណួរនេះគឺការស្របច្បាប់សម្រាប់គ្រប់ភាគីទាំងអស់ ដោយនៅក្នុងនោះមានទាំងដើមបណ្តឹងរដ្ឋប្បវេណីផង ដែលការចូលរួមរបស់គេមិនអាចកម្រិតមកនៅត្រឹមតែការជជែកពិភាក្សាសាមញ្ញមួយស្តីពីពិរុទ្ធភាពដែលមានលក្ខណៈសត្យានុម័តរបស់ជនជាប់ចោទប៉ុណ្ណោះទេ។ វាគឺជាការចាំបាច់ដែលត្រូវមានលទ្ធភាពស្វែងយល់អំពីហេតុផលនៃអាកប្បកិរិយាបែបឧក្រិដ្ឋ ដើម្បីចៀសវាងជាអាទិ៍កុំឲ្យអាកប្បកិរិយាឧក្រិដ្ឋនេះកើតមានឡើងជាថ្មីម្តងទៀត។ម្យ៉ាងទៀត តម្រូវការនៃការស្វែងយល់នេះកាន់តែមានសារៈសំខាន់ទៅទៀត នៅពេលដែលអង្គហេតុទាំងនោះត្រូវបានគេទុកចោលយ៉ាងយូរដោយគ្មានចម្លើយ ហើយថែមទាំងស្ថិតក្នុងភាពអាថកំបាំងទៀតផង[34]។

២៩. ពិតប្រាកដណាស់ វាហាក់ដូចជាជាការអួតអាងពេកដែលជឿថា រឿងក្តីព្រហ្មទណ្ឌមួយ ជាពិសេសនៅពេលដែលរឿងក្តីនេះទាក់ទងនឹងឧក្រិដ្ឋកម្មទៅលើមនុស្សច្រើននាក់ អាចអនុញ្ញាតឲ្យឆ្លើយតបដោយពេញចិត្ត ឬដោយសមហេតុផលទៅនឹងរាល់សំណួររបស់ភាគីនានា ជាពិសេសនោះទៅនឹងសំណួររបស់ជនរងគ្រោះ។ ប៉ុន្តែ វាគឺជាការងារមួយដែលចូលរួមនៅក្នុងការខិតខំ

[34] សូមអាន ការផ្តល់ចម្លើយរបស់អ្នកជំនាញ គឺបណ្ឌិត ឈឹម សុធារ៉ា នៅក្នុងប្រតិចារិកថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ជាអាទិ៍ចាប់ពីទំព័រទី ៦០។




E C C C • E C T C • TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

ប្រឹងប្រែងស្វែងរកការពិត ហើយការសិក្សាអំពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ហេតុផលជាយថាហេតុ និងចរិតលក្ខណៈ ឬចរិតលក្ខណៈផ្នែកផ្លូវចិត្តរបស់គេ គឺដើម្បីជួយសម្រួលដល់ការស្វែងយល់សំណុំរឿង។ ពិតប្រាកដណាស់ នេះគឺជាផលប្រយោជន៍ជាសារវ័ន្តមួយក្នុងចំណោមផលប្រយោជន៍ជាសារវ័ន្តនានានៃការចូលរួមរបស់ជនរងគ្រោះ ដែលអាចចូលរួមនៅក្នុងរឿងក្តីតាមរយៈសំណួរ និងការអត្ថាធិប្បាយរបស់ពួកគេដើម្បីអាចឆ្លើយតបទៅនឹងសំណួរ "ហេតុអ្វី?" នេះ[35]។

៣០. វាជាការសំខាន់ដែលការជជែកពិភាក្សាស្តីពីធាតុផ្សំទាំងអស់នេះអាចប្រព្រឹត្តទៅ ហើយនិងប្រព្រឹត្តទៅដោយពេញលេញនៅក្នុងតុលាការយុត្តិធម៌មួយ។ ម្យ៉ាងទៀត ដើមបណ្តឹងរដ្ឋប្បវេណីប្រហែលអាចមានចំណេះដឹងផ្ទាល់ខ្លួនអំពីប្រវត្តិ ឬចរិតលក្ខណៈរបស់ជនជាប់ចោទ ហើយដើម្បីស្វែងរកយុត្តិធម៌ គឺជាការមានប្រយោជន៍ដែលត្រូវចែករំលែកចំណេះដឹងនេះ។ ម្យ៉ាងវិញទៀត នៅពេលដែលជនរងគ្រោះមិនដឹងថា តើនរណាជាអ្នកធ្វើឲ្យខ្លួនឈឺចាប់នោះ ការជជែកពិភាក្សារបស់តុលាការអាចអនុញ្ញាតឲ្យពួកគេ បង្ហាញអំពីទស្សនៈរបស់ពួកគេទាក់ទងនឹងទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ ដោយនៅក្នុងនោះរួមមានការមិនយល់ ភាពមិនច្បាស់លាស់ ការចោទជាសំណួរនិងការភ័យខ្លាចជាយថាហេតុរបស់ពួកគេ។ ហើយការភ័យខ្លាចក៏អាចបណ្តាលមកពីការមិនស្គាល់អ្នកដទៃផងដែរ។

៣១. មួយវិញទៀត ការដាក់ទោសគឺជាឧបករណ៍ដំបូងគេបង្អស់មួយសម្រាប់បញ្ចប់ភាពចលាចលក្នុងសង្គម និងជួយសម្រួលដល់សំណងទៅលើជនរងគ្រោះ ហើយការដាក់ទោសនេះតែងតែជាអ្វីដែលចាំបាច់ខានមិនបានសម្រាប់ជាមូលដ្ឋាននៃការបង្រួបបង្រួមជាតិ។ ជាអាទិ៍ ការដាក់

---

[35] ប៉ុន្តែបញ្ហានេះអាចបញ្ជាក់ថាត្រឹមត្រូវបានតែនៅពេលដែលគេអាចចោទសួរសំណួរណាក៏បាន។ វាជាការពិតដែលនៅក្នុងក្របខណ្ឌនៃការដឹកនាំការជជែកពិភាក្សា គឺប្រធាន និងអង្គជំនុំជម្រះ ហើយនិងភាគីនានាខ្លួនឯងដែលត្រូវហាមឃាត់ ឬបញ្ចប់សំណួរដែលគ្មានភាពសមហេតុផល ឬដែលមានលក្ខណៈច្រំដែល។ វិធាន ៨៥-១ និង ៩១-៣ អនុញ្ញាតឲ្យប្រធានអង្គជំនុំជម្រះ "ផាត់ចោលពីការជជែកពិភាក្សារាល់អ្វីៗដែលប្រាថ្នាចង់ពន្យារពេលការជជែកពិភាក្សាដោយឥតប្រយោជន៍ ដោយមិនចូលរួមចំណែកនៅក្នុងការបង្ហាញការពិត"។

ទោសត្រូវតែអនុញ្ញាតផងដែរឲ្យជនរងគ្រោះអាចកាត់បន្ថយបាននូវមុខរបួសនៃការឈឺចាប់ដែលខ្លួនបានទទួលរង។ ប៉ុន្តែ ទិសដៅមួយក្នុងចំណោមទិសដៅសំខាន់ៗនៃតុលាការនេះ គឺការបង្រួបបង្រួមជាតិ[36]។ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកថា ដើមបណ្តឹងរដ្ឋប្បវេណីគឺពិតជាមានការទាក់ទងជាមួយដំណើរការបែបនេះ ដោយហេតុថាអង្គជំនុំជម្រះបានអនុញ្ញាតឲ្យពួកគេចោទសួរសាក្សីជាច្រើនដែលលើកឡើងដោយក្រុមការពារក្តី ដោយនៅក្នុងចំណោមសាក្សីទាំងនោះ មានអតីតរដ្ឋអាជ្ញានៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា និងអតីតប្រទេសយូហ្គោស្លាវី[37] និងអតីតអ្នកតាក់តែងសេចក្តីថ្លែងការជាសាកលស្តីពីសិទ្ធិមនុស្ស[38] ដែលត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មលើការអនុវត្តការពិភាក្សាដេញដោលស្តីពីពិរុទ្ធភាព ព្រមទាំងឧប្បត្តិហេតុរបស់វាទាក់ទងនឹងការបង្រួបបង្រួមជាតិ ហើយម្យ៉ាងទៀតស្តីពីប្រធានបទនៃការសុំអភ័យទោស។ នៅក្នុងចំណុចនេះដែរ ដំណើរការមួយបែបនេះអាចធ្វើទៅបានប្រសិនបើវាប្រព្រឹត្តទៅនៅក្នុងភាពច្បាស់លាស់ ហើយកំណត់បានថា ជនរងគ្រោះអាចស្គាល់និងយល់អំពីបុគ្គលិកលក្ខណៈរបស់ជនដែលពួកគេចាត់ទុកថាជាដើមហេតុនៃការឈឺចាប់របស់ពួកគេ។ បញ្ហានេះគឺរឹតតែមានសារៈសំខាន់ទៅទៀតនៅក្នុងបរិបទនៃអង្គជំនុំជម្រះវិសាមញ្ញ ដោយហេតុថា មានអ្នកធ្វើបទអន្តរាគមន៍ជាច្រើនបានសង្កត់ធ្ងន់លើការណ៍ដែលស្លាកស្នាមឈឺចាប់ផ្លូវកាយនិងផ្លូវចិត្តរបស់ជនរងគ្រោះកាន់តែមានលក្ខណៈធ្ងន់ធ្ងរឡើង ដោយសារភាពអមនុស្សធម៌នៃឧក្រិដ្ឋកម្មនានាដែលគេទម្លាក់ទោសទៅលើអង្គភាពអរូបីមួយដែលគេឲ្យឈ្មោះថា "អង្គការ" ដែលអាចប្រើជាឡប់ឡែសម្រាប់បិទបាំងចំពោះរាល់ការស្វែងរកភាពទទួលខុសត្រូវរបស់បុគ្គល[39]។

---

[36] សូមអាន អត្ថបទបុព្វកថានៃកិច្ចព្រមព្រៀងដែលមាននៅក្នុងវិធានផ្ទៃក្នុង ដែលទទួលស្គាល់ជាអាទិ៍ថា ទិសដៅនៃការបង្រួបបង្រួមជាតិគឺជាក្តីបារម្ភដ៏ត្រឹមត្រូវនៃរដ្ឋាភិបាលនិងប្រជាជនកម្ពុជា។

[37] ការស្តាប់ចម្លើយចៅក្រម Richard Goldstone ក្នុងឋានៈជាសាក្សីជំនាញ ប្រតិចារិកថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩។

[38] ការស្តាប់ចម្លើយ Stéphane Hessel ក្នុងឋានៈជាសាក្សីជំនាញ ប្រតិចារិកថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩។

[39] សូមអានផងដែរ ការផ្តល់ចម្លើយរបស់អ្នកជំនាញ គឺបណ្ឌិត ឈឹម សុធារ៉ា ប្រតិចារិកថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ជាអាទិ៍ចាប់ពីទំព័រទី ២០។



E C C C * TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

៣២. ហេតុដូច្នេះ ការមិនយល់ព្រមរបស់ខ្ញុំគឺពិតជាផ្តោតជាសំខាន់ទៅលើតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទៅលើលទ្ធភាពសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងការជជែកពិភាក្សាអំពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ហើយលើសពីនេះគឺទៅលើទស្សនាទាននៃរឿងក្តី។ ខ្ញុំយល់ឃើញថា សេចក្តីសម្រេចដែលប្រកាន់យកដោយអង្គជំនុំជម្រះហាក់ដូចជាផ្ទុះបញ្ចាំងអំពីទស្សនាទានផ្សេងមួយ ដែលមិនទាក់ទងទាំងច្បាប់កម្ពុជា ទាំងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយដែលសេចក្តីសម្រេចនេះបង្កប់នូវការបែងចែកដាច់ពីគ្នានូវការជជែកពិភាក្សាអំពីពិរុទ្ធភាព និងទោស ហើយម្យ៉ាងទៀតមិនផ្តល់ឲ្យជនរងគ្រោះនូវឋានៈជាភាគីនៅក្នុងរឿងក្តីនោះឡើយ។ ចំពោះគំនិតមួយដែលថា បន្ទាប់ពីបានពិនិត្យលើអំណះអំណាងដែលទាក់ទងនឹងពិរុទ្ធភាព ឬគ្មានពិរុទ្ធរបស់ជនជាប់ចោទនោះ ថាការជំនុំជម្រះក្តីបច្ចុប្បន្នស្ថិតនៅក្នុង "ដំណាក់កាលចុងក្រោយ" ហើយដែលនៅក្នុងដំណាក់កាលនេះមានតែតម្លៃនៃធាតុផ្សំដែលត្រូវតែយកមកថ្លឹងថ្លែងសម្រាប់ការកំណត់ទោសជាយថាហេតុណាមួយប៉ុណ្ណោះដែលនឹងត្រូវបានគេលើកយកមកពិភាក្សានោះ គំនិតនេះនាំទៅដល់ការបង្កើតនូវការបែងចែកដាច់ពីគ្នារវាងសវនាការស្តីពីពិរុទ្ធភាព និងសវនាការស្តីពីទោសទៅវិញទេ។ ប៉ុន្តែនៅក្នុងសេចក្តីសម្រេចដែលប្រកាន់យកតាមមតិភាគច្រើនរបស់ខ្លួន អង្គជំនុំជម្រះខ្លួនឯងបានយល់ស្របថា ការបែងចែកដាច់ពីគ្នាបែបនេះមិនត្រូវបានចែងដោយវិធានផ្ទៃក្នុង ឬដោយវិធាននីតិវិធីព្រហ្មទណ្ឌកម្ពុជាទេ[40]។ ម្យ៉ាងទៀត ការបែងចែកដាច់ពីគ្នានេះអាចបង្កជាគ្រោះថ្នាក់ ដោយហេតុថា ត្រូវចំណាយពេលសវនាការអស់ជាច្រើនថ្ងៃដើម្បីពិនិត្យតែទៅលើធាតុផ្សំដែលអាចយកមកគិតគូរដើម្បីធ្វើការកំណត់ទោសនោះ។ គេអាចចោទសួរថាតាមពិតទៅតើអង្គជំនុំជម្រះមិនបានប្រកាន់យកនូវគោលជំហរមួយទាក់ទងនឹងពិរុទ្ធភាពរបស់ជនជាប់ចោទរួចទៅហើយទេ ឬយ៉ាងណា។ ការចោទសួរមួយបែបនេះពិតជាមិនគួរកើតមានទេ ប្រសិនបើការស្តាប់ចម្លើយសាក្សីទាក់ទងនឹងបុគ្គលិកលក្ខណៈ និងអ្នកជំនាញផ្នែកចិត្តសាស្ត្រ និងផ្នែកវិកលវិទ្យា ត្រូវបានគេចាត់ទុកថាស្ថិតនៅទាំងស្រុងក្នុងការជជែកពិភាក្សាមួយដែលមានលក្ខណៈទូលំទូលាយជាងស្តីពីទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទនោះ ដែលមានការ

---

[40] សូមអានកថាខណ្ឌទី១៥ នៃសេចក្តីសម្រេចតាមមតិភាគច្រើនរបស់ចៅក្រមនៃអង្គជំនុំជម្រះ។



E C C C TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

ស្វែងរកការពិតទាំងទៅលើអង្គហេតុដែលលើកឡើងនៅក្នុងការចោទប្រកាន់ ទាំងទៅលើបុគ្គលិកលក្ខណៈរបស់មនុស្សដែលគេបានសន្មត់ថាបានបង្កើតអង្គហេតុទាំងនោះ។

៣៣. គួរតែធ្វើការកត់សម្គាល់ផងដែរថា រហូតមកទល់បច្ចុប្បន្ននេះ ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងការពិភាក្សាលើរាល់ភស្តុតាង រួមទាំងភស្តុតាងដែលទាក់ទងនឹងបុគ្គលិកលក្ខណៈផង ដូចមានអនុវត្តនៅក្នុងប្រទេសជាច្រើនដែលមានប្រពៃណីច្បាប់ស៊ីវិលនោះ មិនដែលត្រូវបានគេចាត់ទុកថាជាការបង្កើតឱ្យមានការបាត់បង់សមភាពនៃកំលាំង ឬដែលអាចប៉ះពាល់ជាគោលការណ៍ដល់សមធម៌នៃរឿងក្តីនោះក៏ទេដែរ។ លើសពីនេះទៅទៀត នៅក្នុងបរិបទដ៏លំបាកមួយដែលបញ្ហានៃទំនុកចិត្តលើអង្គជំនុំជម្រះកំពុងត្រូវបានគេជជែកពិភាក្សា ហើយដែលបញ្ហានៃការផ្ដល់យុត្តិធម៌តាមរយៈអង្គជំនុំជម្រះវិសាមញ្ញ នឹងត្រូវគេយកធ្វើជាឧទាហរណ៍សម្រាប់យុត្តាធិការកម្ពុជាដទៃទៀតនោះ ការណ៍ដែលអាចរក្សាទំនុកចិត្តរបស់សាធារណៈជនបានជារឿងសំខាន់មួយ ហើយទំនុកចិត្តនេះនឹងអាចទទួលបានដោយងាយស្រួល ប្រសិនបើអង្គជំនុំជម្រះយកចិត្តទុកដាក់ក្នុងការធានានូវសិទ្ធិរបស់ជនរងគ្រោះដែលបានតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។

៣៤. រហូតមកទល់ពេលនេះ យុត្តាធិការព្រហ្មទណ្ឌអន្តរជាតិ ឬដែលមានលក្ខណៈអន្តរជាតិ មានឱកាសដ៏កម្រក្នុងការបង្កើតយុត្តិសាស្ត្រមួយស្ដីពីការចូលរួមរបស់ជនរងគ្រោះ ដោយសារតែតួនាទីរបស់ជនរងគ្រោះតែងតែត្រូវបានគេកម្រិតមកនៅត្រឹមតែតួនាទីជាសាក្សី ឬមួយដោយសារថា ការចូលរួមរបស់ជនរងគ្រោះក្នុងនីតិវិធីបែបនេះមានលក្ខណៈថ្មីថ្មោងពេក[41]។ ដូច្នេះ វាជាការលំបាកដែលអះអាងថា នឹងអាចមានបទដ្ឋានអន្តរជាតិសមហេតុសមផលមួយបញ្ជាក់ទៅលើបញ្ហានៃសិទ្ធិនេះ។ ប៉ុន្តែ ដោយបានឃើញការតាក់តែងមាត្រា ៦៨.៣ នៃលក្ខន្តិកៈទីក្រុងរ៉ូមស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាការគួរឱ្យចាប់អារម្មណ៍ដើម្បីដឹងថា តើការតាក់តែងមាត្រានេះវាយតម្លៃថា

[41] សូមអាន វដ្តអាជ្ញារ តទល់នឹង Germain Katanga និង Mathieu Ngudjolo Chui អង្គបុរេជំនុំជម្រះ I (ចៅក្រមតែម្នាក់) នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (CPI) ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨, សំណុំរឿង ICC-01/04-01/07-474 កថាខណ្ឌទី ៣៨។

ការចូលរួមរបស់ជនរងគ្រោះនៅក្នុងការជជែកពិភាក្សាមួយបែបនេះសមស្របទៅនឹងផលប្រយោជន៍របស់ពួកគេដែរឬទេ ហើយអាចនឹងធ្វើឱ្យបានសម្រេចដោយមិនធ្វើឱ្យខូចផលប្រយោជន៍ និងមិនផ្ទុយទៅនឹងសិទ្ធិរបស់ក្រុមការពារក្តី ទៅនឹងការទាមទារឱ្យមានដំណើរការរឿងក្តីមួយប្រកបដោយសមធម៌ និងដោយមិនលម្អៀងដែរ ឬទេ[42]។ គ្រាន់តែកត់សម្គាល់ថា ចំពោះស្ថានភាពនៃយុត្តិសាស្ត្រដែលមាននាពេលនេះ សាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានបង្ហាញរួចហើយថា ពិតមែនតែមិនមែនជា "ភាគី"ក្តី ក៏"ជនរងគ្រោះដែលចូលរួម" នៅក្រោមលក្ខខណ្ឌចាំបាច់មួយចំនួន មានជាអាទិ៍ការបញ្ជាក់ថាផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេមានការពាក់ព័ន្ធនោះ អាចអនុញ្ញាតឱ្យគេដាក់បញ្ចូលភស្តុតាងដែលទាក់ទងនឹងពិរុទ្ធភាព ឬគ្មានពិរុទ្ធរបស់ជនជាប់ចោទ ហើយនឹងអាចតវ៉ាចំពោះភាពអាចទទួលយកបាន ឬភាពសមហេតុសមផលនៃភស្តុតាងនៅក្នុងអំឡុងពេលនៃដំណើរការក្តី។ សាលាឧទ្ធរណ៍ក៏បានយល់ស្របផងដែរថា ការទទួលស្គាល់សិទ្ធិសម្រាប់ជនរងគ្រោះទាំងនេះមិនប៉ះពាល់ដល់គោលការណ៍មួយ ដែលតាមរយៈគោលការណ៍នេះការបង្ហាញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ គឺជាបន្ទុករបស់រដ្ឋអាជ្ញា ហើយក៏មិនប៉ះពាល់ដល់សិទ្ធិរបស់ក្រុមការពារក្តី និងការទាមទារឱ្យមានការជំនុំជម្រះក្តីប្រកបដោយសមធម៌ដែរ[43]។

---

[42] មាត្រា ៦៨.៣ ចែងថា៖ "នៅពេលដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះមានការពាក់ព័ន្ធ តុលាការអនុញ្ញាតឱ្យទស្សនៈនិងក្តីបារម្ភរបស់ពួកគេត្រូវបានបង្ហាញនិងពិនិត្យ នៅក្នុងដំណាក់កាលនីតិវិធីដែលតុលាការយល់ឃើញថាមានលក្ខណៈសមស្រប ហើយដោយមិនធ្វើឱ្យខូចប្រយោជន៍និងផ្ទុយទៅនឹងសិទ្ធិរបស់ក្រុមការពារក្តី ហើយនិងការទាមទារឱ្យមានដំណើរការរឿងក្តីមួយប្រកបដោយសមធម៌និងមិនលម្អៀង។ ទស្សនៈ និងក្តីបារម្ភទាំងនេះអាចសម្តែងឱ្យឃើញតាមរយៈអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ នៅពេលដែលតុលាការយល់ឃើញថាមានលក្ខណៈសមស្រប ដោយអនុលោមតាមវិធាននីតិវិធីនិងភស្តុតាង។"

[43] *រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo* សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (CPI) ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨ លេខ៖ ICC-01/04-1/06 OA9 OA 10។ គឺជាការសំខាន់ដែលត្រូវគូសបញ្ជាក់ថា មានភាពខុសគ្នាជាសារវ័ន្តរវាងស្ថានភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អង្គជំនុំជម្រះវិសាមញ្ញ និងស្ថានភាពរបស់ "ជនរងគ្រោះដែលចូលរួម" នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងខណៈដែលជនរងគ្រោះដែលចូលរួមទាំងនេះមិនមានលក្ខន្តិកៈជាភាគីនៅក្នុងរឿងក្តីទេ។

៣៥. នៅទីបញ្ចប់ ការមិនយល់ស្របរបស់ខ្ញុំក៏ទាក់ទងផងដែរទៅនឹងបញ្ហានៃភាពស៊ីសង្វាក់គ្នាដែលសេចក្ដីសម្រេចទាំងនេះបានធ្វើឡើងមុនការបញ្ចប់សវនាការស្ដីពីការបង្ហាញភស្តុតាងបន្តិចប៉ុណ្ណោះ។ ជាការពិត តាមភាពជាក់ស្ដែង និងជាច្រើនលើកច្រើនសារ[44] ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតរហូតមកទល់ពេលនេះ ឲ្យចោទសួរនូវសំណួរដែលទាក់ទងទៅនឹងបុគ្គលិកលក្ខណៈ ទាំងទៅជនជាប់ចោទ ទាំងទៅសាក្សី និងអ្នកជំនាញ ទោះជាសាក្សីផ្ទាល់នៅក្នុងអង្គហេតុដែលលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬក៏ជាសាក្សីដែលសន្មត់ថាអាចបញ្ជាក់ឡើងវិញនូវអង្គហេតុទាំងនោះនៅក្នុង "បរិបទផ្នែកប្រវត្តិសាស្ត្រនិងផ្ទាល់ខ្លួន" របស់វាក៏ដោយ។ ដូច្នេះ ការហាមឃាត់ដែលធ្វើឡើងនៅដំណាក់កាលនេះគឺពិតជាផ្ទុយគ្នាទាំងស្រុងទៅនឹងបែបបទនៃការជជែកពិភាក្សាបានធ្វើឡើងរហូតមកទល់នឹងពេលនេះ ជាអាទិ៍នៅក្នុងពេលពិនិត្យអង្គហេតុ ឬអាកប្បកិរិយារបស់ជនជាប់ចោទដែលមិនមានទំនាក់ទំនងដោយផ្ទាល់ណាមួយទាល់តែសោះជាមួយនឹងការជជែកពិភាក្សាលើភាពគ្មានពិរុទ្ធ ឬលើពិរុទ្ធភាពរបស់ជនជាប់ចោទ ដោយហេតុថាអង្គហេតុទាំងនេះស្ថិតនៅមុនអង្គហេតុដែលបានលើកឡើងនៅក្នុងការចោទប្រកាន់ទៅទៀត[45]។

៣៦.ម្យ៉ាងវិញទៀត គឺជាការពិតជាក់ស្ដែងដែលថា ទាំងការវិភាគផ្នែកចិត្តសាស្ត្រ ឬផ្នែកវិកលវិទ្យានៃបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ក៏ដូចជាសេចក្ដីលម្អិតនៃប្រវត្តិរូបនិងអាកប្បកិរិយារបស់ជនជាប់ចោទនៅមុន ឬក៏នៅក្រោយអង្គហេតុ មានអត្ថប្រយោជន៍តែនៅពេលដែលវាអាចអនុញ្ញាតឲ្យស្វែងយល់ឲ្យបានប្រសើរជាងមុននូវការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានចោទប្រកាន់តែប៉ុណ្ណោះ។ អះអាងថាកោសល្យវិច័យដែលធ្វើឡើងដោយអ្នកជំនាញផ្នែកវិកលវិទ្យា ឬអ្នកជំនាញផ្នែកចិត្តសាស្ត្រគ្រាន់តែអាចឲ្យវាយតម្លៃអំពីស្ថានសម្រាលទោស ឬស្ថានទម្ងន់ទោស ដែលត្រូវតែ

---

[44] ទាក់ទងនឹងប្រធានបទនេះ សូមអានអំណះអំណាងដែលលើកឡើងដោយមេធាវីអន្តរជាតិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺមេធាវី Werner នៅក្នុងឱកាសនៃការពិគ្រោះយោបល់ដោយអង្គជំនុំជម្រះ ស្ដីពីគោលជំហររបស់ភាគីនានាទាក់ទងនឹងបញ្ហាដែលចង់ដឹងថា តើដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានគេអនុញ្ញាតឲ្យសួរសំណួរទាក់ទងនឹងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទដែរឬទេ? ប្រតិចារិកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ពីកថាខណ្ឌទី ៦៥ ដល់កថាខណ្ឌទី ៦៧។

[45] សូមអានជាអាទិ៍ការជជែកពិភាក្សាស្ដីពីការចូលរួមរបស់ជនជាប់ចោទ នៅក្នុងការដឹកនាំមន្ទីរឃុំឃាំងមួយដែលមានអត្ថិភាពនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងដែលមានឈ្មោះថា ម១៣។

យកមកគិតគូរដើម្បីធ្វើការកំណត់ទោស ហើយថាកោសល្យវិច័យនោះគ្រាន់តែមានកម្មវត្ថុដើម្បីវាយតម្លៃឲ្យបានប្រសើរជាងមុនអំពី "ចរិតលក្ខណៈ" របស់ជនជាប់ចោទ ដែលត្រូវបានកំណត់ថានៅក្នុងនោះមានបុគ្គលិកលក្ខណៈ ចរិតឬកពារ សុចរិតធម៌ និងកេរ្តិ៍ឈ្មោះ[46]របស់ជនជាប់ចោទនោះ គឺមិនត្រឹមតែ "កាត់បន្ថយ" ជាពិសេសដល់ដំណើរការរបស់អ្នកជំនាញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្ទុយទៅនឹងការពិតទៀតផង នៅពេលដែលវាពិតជាស្ថិតនៅក្នុងបេសកកម្មរបស់អ្នកជំនាញដែលត្រូវប្រកាសអំពីអត្ថិភាពនៃជម្ងឺជាយថាហេតុ ដែលអាចប៉ះពាល់ដល់ទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ។ ប៉ុន្តែ អង្គជំនុំជម្រះបានកំណត់ជាមុនអំពីខ្លឹមសារនៃការជជែកពិភាក្សា ហើយដោយមិនរង់ចាំការផ្តល់ចម្លើយផ្ទាល់មាត់របស់អ្នកជំនាញ អង្គជំនុំជម្រះបានធ្វើការសម្រេចជាឯកតោភាគីថា របាយការណ៍របស់អ្នកជំនាញទាំងនោះនឹងមិនមានឧបត្តិហេតុណាមួយលើបញ្ហាទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទទេ ហើយរបាយការណ៍នោះគ្រាន់តែធ្វើឲ្យមានការចាប់អារម្មណ៍ដល់ការពិភាក្សាលើការសម្រេចអំពីទោសជាយថាហេតុមួយតែប៉ុណ្ណោះ។

៣៧. គួររំឭកថា នៅក្នុងចំណោមគោលការណ៍ជាសារវ័ន្តដែលអាចយកមកអនុវត្តបាននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ អង្គជំនុំជម្រះទាំងឡាយត្រូវខិតខំប្រឹងប្រែងបកស្រាយ "ច្បាប់ស្តីពីកាបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជាផ្ទៃក្នុង ដោយធ្វើយ៉ាងណាដើម្បីការពារជានិច្ចកាលនូវផលប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ និងធ្វើយ៉ាងណាដើម្បីធានាសុវត្ថិភាពគតិយុត្តព្រមទាំងតម្លាភាពនៃនីតិវិធី ..."[47]។ ខ្ញុំយល់ឃើញថា សេចក្តីសម្រេចដែលប្រកាន់យកដោយអង្គជំនុំជម្រះសាលាដំបូង ហាក់ដូចជាបង្កើតនូវភាពមិនច្បាស់លាស់មួយដែលអាចប៉ះពាល់ដល់សុវត្ថិភាពគតិយុត្តនៃនីតិវិធី មិនត្រឹមតែដោយគិតដល់លក្ខណៈជឿនលឿនទៅមុខនៃសវនាការនៅក្នុងសំណុំរឿងលេខ ០០១ ប៉ុណ្ណោះទេ ប៉ុន្តែក៏គិតគូរផងដែរដល់ការជាប់ពាក់ព័ន្ធដែលអាចកើតមាននៅក្នុងសំណុំរឿងផ្សេងទៀត ដែល

---

[46] សូមអានកថាខណ្ឌទី៤៤ នៃសេចក្តីសម្រេចតាមមតិភាគច្រើនរបស់ចៅក្រមនៃអង្គជំនុំជម្រះ។

[47] វិធាន ២១ ១) នៃ វិធានផ្ទៃក្នុង។



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE · E C C C · C E T C

បច្ចុប្បន្នកំពុងនៅក្នុងចំណាត់ការសហចៅក្រមស៊ើបអង្កេត[48]។ ដូច្នេះ យើងចង់ឲ្យមានការពន្យល់បំភ្លឺមួយអំពីវិធានផ្ទៃក្នុង។ ផ្ទៃ. NWR

ធ្វើនៅភ្នំពេញ ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩

ចៅក្រម Jean-Marc Lavergne

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • C B T C

[48] សូមរំឭកថា នៅដំណាក់កាលនេះ ដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំអោយមានកិច្ចស៊ើបសួរ ឬសួរសំណួរនៅក្នុងពេលតទល់គ្នាដែលអាចទាក់ទងនឹងបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ។